# កម្មវិធីសិក្សាសម្រាប់ការពង្រឹងសមត្ថភាពលើការសិក្សាស្រាវជ្រាវអំពីជំងឺរបេង

## ម៉ូឌុលទី៣៖ វិធីសាស្ត្រស្រាវជ្រាវបែបគុណវិស័យ និងការវិភាគ

មីនា ២០២៣

មជ្ឈមណ្ឌលជាតិកំចាត់រោគរបេង និងហង់សិន

USAID
FROM THE AMERICAN PEOPLE

TB DIAH
Tuberculosis Data, Impact Assessment and Communications Hub

# កម្មវិធីសិក្សាសម្រាប់ការពង្រឹងសមត្ថភាពលើការសិក្សាស្រាវជ្រាវអំពីជំងឺរបេង

## ម៉ូឌុលទី៣៖វិធីសាស្ត្រស្រាវជ្រាវបែបគុណវិស័យ និងការវិភាគ

Kai-Lih Liu, Ph.D., MPH, TB Research Capacity Building Advisor, TB DIAH Cambodia Team

**TB DIAH**

University of North Carolina
123 West Franklin Street, Suite 330
Chapel Hill, North Carolina 27516 USA
Phone: 919-445-9350 | Fax: 919-445-9353
hub@tbdiah.org
www.tbdiah.org

This publication was produced with the support of the United States Agency for International Development (USAID) under the terms of the TB Data, Impact Assessment and Communications Hub (TB DIAH) Associate Award No. 7200AA18LA00007. TB DIAH is implemented by the University of North Carolina at Chapel Hill, in partnership with John Snow, Inc. Views expressed are not necessarily those of USAID or the United States government.
Publication ID Number PR-23-004

## មាតិកា


**មាតិកា** ........ **3**

**អក្សរកាត់** ........ **4**

**សេចក្តីថ្លែងអំណរគុណ** ........ **5**

សកម្មភាពនៃការពង្រឹងសមត្ថភាព ........ 6

ម៉ូឌុលពង្រឹងសមត្ថភាពស្រាវជ្រាវ ........ 8

**ម៉ូឌុលការពង្រឹងសមត្ថភាពស្រាវជ្រាវទី ៣** ........ **9**

គោលបំណង ........ 9

ទិដ្ឋភាពទូទៅ ........ 9

យុទ្ធសាស្ត្រក្នុងការបណ្តុះបណ្តាល ........ 11

គោលដៅនៃការសិក្សា ........ 11

**ខ្លឹមសារនៃកម្មវិធីសិក្សា** ........ **15**

សម្រាប់ការស្រាវស្រាវបែបគុណវិស័យ ........ 16

វិធីសាស្ត្រក្នុងការសិក្សាស្រាវជ្រាវបែបគុណវិស័យ ........ 26

ការគ្រប់គ្រងទិន្នន័យ និងការវិភាគទិន្នន័យបែបគុណវិស័យ ........ 41

សេចក្តីសន្និដ្ឋាន ........ 52

**ឯកសារយោង** ........ **53**

**ឧបសម្ព័ន្ធ** ........ **54**

តេស្តមុនវគ្គ ម៉ូឌុលទី ៣ ........ 54

សំណួរតេស្តក្រោយវគ្គ ........ 55

ចម្លើយសម្រាប់តេស្តមុន និងក្រោយវគ្គ ........ 57

# អក្សរកាត់

| | |
|---|---|
| CENAT | National Center for Tuberculosis and Leprosy Control |
| FGD | focus group discussion |
| IDI | in-depth interview |
| NIPH | National Institute of Public Health |
| NSP | National Strategic Plan |
| NTP | The National Tuberculosis Program (Cambodia) |
| STAR | Sustaining Technical and Analytical Resources |
| TB | tuberculosis |
| TB DIAH | Tuberculosis Data, Impact Assessment and Communication Hub |
| USAID | United States Agency for International Development |
| WHO | World Health Organization |

# សេចក្តីថ្លែងអំណរគុណ

កម្មវិធីសិក្សានេះត្រូវបានបង្កើតឡើងដោយ TB DIAH រួមសហការជាមួយ USAID STAR និងវិទ្យាស្ថានជាតិសុខភាពសាធារណៈ (NIPH) នៅកម្ពុជា។ យើងខ្ញុំសូមថ្លែងអំណរគុណចំពោះលោក**វេជ្ជបណ្ឌិត** ហួត ចាន់យុដា ប្រធានមជ្ឈមណ្ឌលជាតិកំចាត់រោគរបេង និងហង់សិន (CENAT) និងលោក**វេជ្ជបណ្ឌិត** សុង ង៉ាក់ អ្នកឯកទេសគ្រប់គ្រងកម្មវិធីរបេងរបស់ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID) ប្រចាំប្រទេសកម្ពុជា ចំពោះការរបស់ពួកគេនៅក្នុងសកម្មភាពនៃការពង្រឹងសមត្ថភាពសិក្សស្រាវជ្រាវអំពីជំងឺរបេងនេះ។ អ្នកចូលរួមទាំងអស់ដែលមកពីមជ្ឈមណ្ឌលជាតិកំចាត់រោគរបេង និងហង់សិន (CENAT) បានផ្តល់មតិកែលម្អដ៏មានតម្លៃសម្រាប់កម្មវិធីសិក្សានេះ។

ថ្លែងអំណរគុណយ៉ាងពិសេសចំពោះ៖

**អ្នកផលិតកម្មវិធី៖**

- បណ្ឌិត **KAI-LIH LIU**
  ទីប្រឹក្សាបច្ចេកទេសការពង្រឹងសមត្ថភាពលើការសិក្សាស្រាវជ្រាវអំពីជំងឺរបេង TB DIAH កម្ពុជា
- លោក **ម៉ែន ឈាន** ប្រធានក្រុមដឹកនាំការងារ TB DIAH កម្ពុជា

**អ្នកត្រួតពិនិត្យ៖**

- **វេជ្ជ. អាន់ យ៉ុម** ទីប្រឹក្សាបច្ចេកទេស USAID STAR
- **វេជ្ជ. ឃុន គឹមអ៊ាម** អនុប្រធានមជ្ឈមណ្ឌលជាតិកំចាត់រោគរបេង និងហង់សិន
- គណៈគ្រប់គ្រងចំណេះដឹង (KM), TB DIAH

**អ្នកបកប្រែ និងកែសម្រួល៖**

- **ជៀន សម្ផស្ស** គ្រូបង្រៀននៃវិទ្យាស្ថានជាតិសុខភាពសារធារណៈ NIPH
- **វេជ្ជ. ឃុន គឹមអ៊ាម** អនុប្រធានមជ្ឈមណ្ឌលជាតិកំចាត់រោគរបេង និងហង់សិន

**ជំនួយការវគ្គបណ្តុះបណ្តាល៖**

- អ្នកស្រី **សៅ សារ៉ាឌី** ទីប្រឹក្សាបច្ចេកទេស TB DIAH កម្ពុជា

**ជំនួយលើផ្នែករដ្ឋបាល៖**

- **វេជ្ជ. ជុំ សុផា** ទីប្រឹក្សាបច្ចេកទេសជំងឺរបេង ក្រុមការងារ TB DIAH កម្ពុជា

## សេចក្តីផ្តើម

ដើម្បីសម្រេចបាននូវគោលដៅយុទ្ធសាស្រ្តបញ្ចប់ជំងឺរបេងនៅត្រឹមឆ្នាំ២០៣៥ ប្រទេសជាច្រើនចាំបាច់ត្រូវពន្លឿនការឆ្លើយតបរបស់ខ្លួនចំពោះជំងឺរបេងជាបន្ទាន់។ បញ្ហាប្រឈមចម្បងមួយក្នុងចំណោមបញ្ហាប្រឈមសំខាន់ៗចំនួនបីដែលបានលើកឡើងដោយអង្គការសុខភាពពិភពលោកនៅឯកិច្ចប្រជុំកំពូល ស្តីអំពីជំងឺរបេងនាថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៨ នៅទីក្រុងញូវយ៉កសហរដ្ឋអាមេរិក គឺផ្តោតសំខាន់ទៅលើ "ការស្វែងរកការលើកទឹកចិត្តដើម្បីជំរុញការរកឱ្យឃើញនូវការធ្វើរោគវិនិច្ឆ័យជំងឺរបេង និងឱសថថ្មីៗ ការវិនិយោគផ្ទាល់លើការធ្វើការសិក្សាស្រាវជ្រាវ ជាពិសេសនៅពេលពួកគេមានគោលបំណងធ្វើឱ្យប្រសើរឡើងនូវគុណភាពនៃការធ្វើរោគវិនិច្ឆ័យ ការព្យាបាល និងការថែទាំជំងឺរបេង»។

TB DIAH កំពុងបង្កើត និងអនុវត្តសកម្មភាពពង្រឹងសមត្ថភាពលើការសិក្សាស្រាវជ្រាវអំពីជំងឺរបេង ដោយមានកិច្ចសហការពីទីប្រឹក្សាបច្ចេកទេស USAID STAR និងវិទ្យាស្ថានជាតិសុខភាពសាធារណៈ (NIPH)។

គោលបំណងរួមនៃសកម្មភាពពង្រឹងសមត្ថភាពលើការសិក្សាស្រាវជ្រាវអំពីជំងឺរបេងទាំងនេះ គឺសម្រាប់មន្ត្រីនៃផ្នែកស្រាវជ្រាវរបស់មជ្ឈមណ្ឌលជាតិកំចាត់រោគរបេង និងហង់សិន (CENAT) ដើម្បីអភិវឌ្ឍជំនាញជាក់ស្តែងក្នុងការធ្វើការសិក្សាស្រាវជ្រាវបែបប្រតិបត្តិ ការវិភាគទិន្នន័យ បោះពុម្ពផ្សាយនូវលទ្ធផលនៃការសិក្សាស្រាវជ្រាវ និងលើកកម្ពស់ការផ្លាស់ប្តូរនៅក្នុងគោលនយោបាយ និងការអនុវត្តជំងឺរបេង។

អត្ថប្រយោជន៍នៃការចូលរួមក្នុងការពង្រឹងសមត្ថភាពលើការសិក្សាស្រាវជ្រាវនេះរួមមានៈ

1. ទទួលបាននូវជំនាញជាក់លាក់ក្នុងការអនុវត្តដំណើរការស្រាវជ្រាវបែបប្រតិបត្តិទាំងមូល ចាប់ពីគោលមូលដ្ឋានគ្រឹះ រហូតដល់ការបោះពុម្ព និងការផ្សព្វផ្សាយនូវលទ្ធនៃការសិក្សាស្រាវជ្រាវនេះ។
2. បទពិសោធន៍ក្នុងការសិក្សា និងចែករំលែកចំណេះដឹងនៅក្នុងក្រុមដែលកំពុងចូលរួម ក៏ដូចជាការផ្លាស់ប្តូរបទពិសោធន៍ជាមួយអ្នកសម្របសម្រួលដែលមានបទពិសោធន៍ក្នុងការធ្វើការសិក្សាស្រាវជ្រាវបែបប្រតិបត្តិ។
3. ឱកាសសម្រាប់អ្នកចូលរួមក្នុងការបង្ហាញបទពិសោធន៍ផ្ទាល់ខ្លួន បង្កើតពិធីសារស្រាវជ្រាវផ្ទាល់ខ្លួន ការមើលឃើញពីការសិក្សាស្រាវជ្រាវបែបប្រតិបត្តិ និងការរៀបចំសម្រាប់ទំនួលខុសត្រូវក្នុងការសិក្សាស្រាវជ្រាវ និងភាពជាអ្នកដឹកនាំការសិក្សាស្រាវជ្រាវនៅក្នុងប្រទេសកម្ពុជា។

អ្នកចូលរួមត្រូវបានលើកទឹកចិត្តយ៉ាងមុតមាំក្នុងការពង្រឹងសមត្ថភាពជាជំហានៗ សម្រាប់ការសិក្សាស្រាវជ្រាវបែបប្រតិបត្តិ និងបង្កើនប្រសិទ្ធភាព ដោយមានការគាំទ្រដ៏មានសក្តានុពល ពីវិទ្យាស្ថានជាតិសុខភាពសាធារណៈ និងភាគីពាក់ព័ន្ធលើផ្នែកស្រាវជ្រាវផ្សេងៗទៀត។

## សកម្មភាពនៃការពង្រឹងសមត្ថភាព

TB DIAH នឹងសហការយ៉ាងជិតស្និទ្ធជាមួយទីប្រឹក្សាបច្ចេកទេស USAID STAR និងគ្រូបង្ហាត់បង្រៀនពីវិទ្យាស្ថានជាតិសុខភាពសាធារណៈរួមទាំងការបកប្រែកម្មវិធីសិក្សា (ពីភាសាអង់គ្លេសទៅជាខ្មែរ) ការសម្របសម្រួលសិក្ខាសាលា និងការគាំទ្រលើការសិក្សាស្រាវជ្រាវ។ វាក៏អាចធ្វើជាការសិក្សាស្រាវជ្រាវរបស់មន្ត្រីសម្រាប់ធ្វើជានិក្ខេបបទស្រាវជ្រាវថ្នាក់អនុបណ្ឌិតរបស់ពួកគេនៅវិទ្យាស្ថានជាតិសុខភាពសាធារណៈជាដើម។

ម៉ូឌុលទាំង ៥ សម្រាប់វគ្គបណ្តុះបណ្តាលស្រាវជ្រាវបែបប្រតិបត្តិទាំងនេះ គឺជាបរិបទចម្បងដែលបានអនុវត្តនៅក្នុងសកម្មភាពពង្រឹងសមត្ថភាពសម្រាប់មន្ត្រីស្រាវជ្រាវមជ្ឈមណ្ឌល

ជាតិកំចាត់រោគរបេង និងហង់សិន ចាប់ពីខែមករាដល់ខែកញ្ញា ឆ្នាំ២០២៣។ ជាតុផ្សំនៃសកម្មភាពដែលមានរយៈពេលមួយឆ្នាំត្រូវបានពិពណ៌នាដូចខាងក្រោម៖

កម្មវិធីបណ្តុះបណ្តាល

នៅក្នុងម៉ូឌុលនៃវគ្គបណ្តុះបណ្តាលស្រាវជ្រាវនីមួយៗត្រូវមានខ្លឹមសារនៃការបង្រៀន ការកំណត់ចំណាំ លំហាត់ និងចម្លើយ។ ម៉ូឌុលនៃវគ្គបណ្តុះបណ្តាលទាំងប្រាំនេះនឹងមានជាឯកសារបោះពុម្ពផ្សាយ និងច្បាប់ចម្លងអេឡិចត្រូនិក ជាភាសាអង់គ្លេស និងជាភាសាខ្មែរ។

សិក្ខាសាលាបណ្តុះបណ្តាល

សិក្ខាសាលាបណ្តុះបណ្តាលដែលមានរយៈពេលពីរថ្ងៃនឹងធ្វើឡើងសម្រាប់ម៉ូឌុលនីមួយៗ៖ សិក្ខាសាលាចំនួន ៣ ធ្វើនៅរាជធានីភ្នំពេញ និង ២ ធ្វើនៅខេត្តផ្សេងៗទៀត។ មន្ត្រីស្រាវជ្រាវរបស់មជ្ឈមណ្ឌលជាតិកំចាត់រោគរបេងចំនួនចាប់ពី ១០ ទៅ ១៥ នាក់ នឹងត្រូវបានចាត់តាំង និងអញ្ជើញឱ្យចូលរួមក្នុងសិក្ខាសាលាបណ្តុះបណ្តាលទាំង ៥ នេះ។ អ្នកសម្របសម្រួលសម្រាប់ការបណ្តុះបណ្តាលនេះមកពី TB DIAH, USAID-STAR និងពីវិទ្យាស្ថានជាតិសុខភាពសាធារណៈរបស់ក្រសួងសុខាភិបាល។

ការណែនាំ **“On-the-Job”**

បន្ថែមលើម៉ូឌុលបណ្តុះបណ្តាលទាំងប្រាំនេះ គឺមានជំនួយមូលនិធិតូចៗចំនួន២ ដែលសម្រាប់ជួយគាំទ្រនៅក្នុងការស្រាវជ្រាវបែបប្រតិបត្តិ ដែលមូលនិធិទាំងនេះ នឹងផ្តល់ជូនដល់មន្ត្រីស្រាវជ្រាវរបស់មជ្ឈមណ្ឌលជាតិកំចាត់រោគរបេង និងហង់សិន។ ថវិកា ឬមូលនិធិតិចតួចនេះនឹងត្រូវបានបង្កើតឡើង និងជួយណែនាំដោយក្រុម TB DIAH និង USAID STAR។ ការណែនាំពី "on-the-job" នេះនឹងមានរយៈពេលប្រហែលប្រាំបួនខែ រួមមានសំណួរស្រាវជ្រាវ ការបង្កើតវិធីសាស្ត្រនៃការសិក្សាពិធីសារនៃការសិក្សាស្រាវជ្រាវការប្រមូលទិន្នន័យ ឬទទួលបានទិន្នន័យការវិភាគទិន្នន័យ និងការសរសេរឯកសារនៃការសិក្សាស្រាវជ្រាវ។

តារាងពេលវេលានៃការពង្រឹងសមត្ថភាព

| | មករា-មីនា ២០២៣ | មេសា-មិថុនា ២០២៣ | កក្កដា-កញ្ញា ២០២៣ |
|---|---|---|---|
| ម៉ូឌុលទី ១ | មករា ២០២៣ | | |
| **ម៉ូឌុលទី ២** | **មីនា ២០២៣** | | |
| ម៉ូឌុលទី ៣ | មីនា ២០២៣ | | |
| ម៉ូឌុលទី ៤ | | ឧសភា ២០២៣ | |
| ម៉ូឌុលទី ៥ | | | មិថុនា ២០២៣ |
| ការណែនាំ "On-the-Job" | √ | √ | √ |

## ម៉ូឌុលពង្រឹងសមត្ថភាពស្រាវជ្រាវ

ម៉ូឌុលចំនួនប្រាំនៃការពង្រឹងសមត្ថភាពស្រាវជ្រាវនឹងត្រូវបានបង្កើតឡើង និងដំណើរការជាភាសាអង់គ្លេស និងជាភាសាខ្មែរដោយ TB DIAH រួមមានៈ

- មូលដ្ឋានគ្រឹះអេពីដេមីសាស្ត្រ និងក្រមសីលធម៌សម្រាប់ការសិក្សាស្រាវជ្រាវជាមូលដ្ឋាន
- វិធីសាស្ត្រស្រាវជ្រាវបែបបរិមាណវិស័យ
- **វិធីសាស្ត្រស្រាវជ្រាវបែបគុណវិស័យ  និងការវិភាគទិន្នន័យ (សិក្ខាសាលាកំពុងដំណើរការ)**
- ជីវស្ថិតិវិទ្យា និងការវិភាគទិន្នន័យបែបបរិមាណ
- វេយ្យាករណ៍ភាសារអង់គ្លេស និងការសរសេររបាយការណ៍ស្រាវជ្រាវ។

ម៉ូឌុលការពង្រឹងសមត្ថភាពស្រាវជ្រាវទី ៣




**រូបទី១. ចំណងជើងសិក្ខាសាលាទី ៣**

គោលបំណង

សម្រាប់អ្នកសិក្សាស្រាវជ្រាវជំងឺរបេង

ការស្រាវជ្រាវបែបគុណវិស័យត្រូវបានសិក្សាស្វែងរកដើម្បីបំភ្លឺអំពីមូលហេតុជាក់លាក់នៃការគ្រប់គ្រងជំងឺរបេង និងការខិតខំប្រឹងប្រែងថែទាំជំងឺស្ទួត ទាំងការទទួលបានជោគជ័យ និងទាំងការមិនបានជោគជ័យនិងរបៀបយ៉ាងណាដែលពួកគេអាចធ្វើឱ្យប្រសើរឡើង។ ការសិក្សាស្រាវជ្រាវបែបគុណវិស័យអាច ផ្តោតលើបទពិសោធន៍នៃកត្តាចម្រុះ និងផលប៉ះពាល់របស់វា។ ការស្រាវជ្រាវដែលជួយក្នុងការជម្នះបញ្ហាប្រឈមលើការផ្តល់ការថែទាំផ្នែកសុខភាព (ឧទាហរណ៍៖ ការបង្ការជំងឺរបេង ការទទួលបានសេវា ការធ្វើរោគវិនិច្ឆ័យ និងការគោរពតាមវេជ្ជបញ្ជា គឺមានលក្ខណៈល្អសម្រាប់អ្នកដែលធ្វើការវិភាគលើបញ្ហា និងទ្វេបញ្ហា ។ របាយការណ៍បែបគុណវិស័យដែលល្អ គឺមានការបកស្រាយពីសក្តានុពលសង្គម យេនឌ័រ វប្បធម៌ សេដ្ឋកិច្ច ឬការផ្លាស់ប្តូរគោលនយោបាយ ការស្វែងរកករណី ការធ្វើរោគវិនិច្ឆ័យ និងលទ្ធផលនៃការព្យាបាល។

ទិដ្ឋភាពទូទៅ

ម៉ូឌុលទី ៣ នេះ រួមមានសមាសធាតុដូចខាងក្រោម

**ការណែនាំអំពីការស្រាវជ្រាវបែបគុណវិស័យវិស័យ៖**

- គោលបំណងនៃការស្រាវជ្រាវបែបគុណវិស័យគុណវិស័យ
- ភាពខុសគ្នារវាងការស្រាវជ្រាវបែបគុណវិស័យគុណវិស័យ និងបរិមាណ

**វិធីសាស្ត្រស្រាវជ្រាវបែបគុណវិស័យគុណវិស័យ៖**

- ការសម្ភាសស៊ីជម្រៅ (IDI)
- ការពិភាក្សាជាក្រុមស៊ីជម្រៅ (FGD)
- ការសង្កេតដោយផ្ទាល់
- ករណីសិក្សា ឬរឿងរ៉ាវខ្សែជីវិត

**ការបង្កើតវិធីសាស្ត្រស្រាវជ្រាវបែបគុណវិស័យគុណវិស័យ**

- រៀបចំវិធីសាស្ត្រស្រាវជ្រាវបែបគុណវិស័យគុណវិស័យ និងសំណួរសម្ភាស
- ដំណើរការប្រមូលទិន្នន័យបែបគុណវិស័យ

**ការគ្រប់គ្រងទិន្នន័យបែបគុណវិស័យ និងការវិភាគស៊ីជម្រៅ**

- ថតសំឡេង និងបំណកស្រាយសំឡេងជាអក្សរ
- ការវិភាគទិន្នន័យជាមួយកម្មវិធីអ៊ិចសែល និងអ៊ិនវីវ៉ូ

**ការបង្ហាញ និងការពិភាក្សាលើលទ្ធផលស្រាវជ្រាវគុណវិស័យ**

## យុទ្ធសាស្រ្តក្នុងការបណ្តុះបណ្តាល

ម៉ូឌុលនេះរួមបញ្ចូលការបង្រៀនចំនួន ២ ដង (២ម៉ោងម្តង) ទី១
ការពិភាក្សាលើការបង្កើតវិធីសាស្រ្តនៃការសិក្សា (២ទៅ៣ ម៉ោង) ការប្រមូលទិន្នន័យ និងការវិភាគទិន្នន័យ (៦ម៉ោង) ការពិភាក្សាចុងក្រោយ (២ម៉ោង) ក៏ដូចជាការវាយតម្លៃពីសមត្ថភាពមុនវគ្គ និងតេស្តក្រោយវគ្គបណ្តុះបណ្តាល (១៥នាទីក្នុងមួយវគ្គ)។

ដោយអនុវត្តឧទាហរណ៍នៃការស្រាវជ្រាវជាក់ស្តែងពីការរំលឹកទ្រឹស្តីនៃការស្រាវជ្រាវ និងរបាយការណ៍បច្ចេកទេសថ្នាក់ជាតិ អ្នកសម្របសម្រួលនឹងដឹកនាំសកម្មភាពដូចខាងក្រោម ដោយពន្យល់ជាភាសាខ្មែរ៖

- ការពិភាក្សាអំពីភាពខុសគ្នារវាងវិធីសាស្រ្តស្រាវជ្រាវបែបគុណវិស័យ និងបែបបរិមាណ
- ការណែនាំអំពីវិធីសាស្រ្តនៃការស្រាវជ្រាវបែបគុណវិស័យគុណវិស័យ
- ការជួយជាជំហ៊ានៗ តាមរយៈដំណើរការស្រាវជ្រាវបែបគុណវិស័យគុណវិស័យ និងដំណើរការក្នុងការអនុវត្តតាមតំបន់គោលដៅ
- បង្ហាញពីរបៀបគ្រប់គ្រង និងវិភាគទិន្នន័យបែបគុណវិស័យ
- ការពិនិត្យឡើងវិញ និងបង្ហាញពីវិធីសាស្រ្តស្រាវជ្រាវបែបគុណវិស័យ និងលទ្ធផលនៃការស្រាវជ្រាវ

## គោលដៅនៃការសិក្សា

នៅចុងបញ្ចប់នៃម៉ូឌុលទី ៣ អ្នកចូលរួមនឹងទទួលបាន៖

១) អាចជ្រើសរើសវិធីសាស្រ្តស្រាវជ្រាវបែបគុណវិស័យគុណវិស័យ សម្រាប់ផែនការស្រាវជ្រាវរបស់ពួកគេ
២) ស្វែងយល់ពីការបង្កើតការសិក្សាស្រាវជ្រាវនៅក្នុងការធ្វើសម្ភាសបែបស៊ីជម្រៅ ក្រុមពិភាក្សាស៊ីជម្រៅ (FGD) ការអង្កេតជាលក្ខណៈរចនាសម្ព័ន្ធ(structural observation) និងវិធីសាស្រ្តគុណវិស័យផ្សេងៗទៀត
៣) អាចបង្កើត និងការប្រមូលទិន្នន័យបែបគុណវិស័យ តាមរយៈការអនុវត្តការប្រមូលទិន្នន័យផ្ទាល់
៤) គ្រប់គ្រង និងការវិភាគទិន្នន័យបែបគុណវិស័យ
៥) បង្ហាញដោយសង្ខេបពីកិច្ចការស្រាវជ្រាវបែបគុណវិស័យវិស័យរបស់ពួកគេ

របៀបវារៈ

| ពេលវេលា | ប្រធានបទ/សកម្មភាព | អ្នកសម្របសម្រួល |
|---|---|---|
| ០៩ មីនា ឆ្នាំ២០២៣ (ថ្ងៃទី១) | | |
| ៨:២០–៨:៥៥ | ការអញ្ជើញមកដល់នៃវាគ្មិនកិត្តិយស អ្នកសម្របសម្រួល និងអ្នកចូលរួម | **ជុំ សុផា** |
| ៨:៥៥–៩:០០ | គោរពភ្លេងជាតិ | **ជុំ សុផា** |
| ៩:០០–៩:១៥ | **កិច្ចបើកវគ្គបណ្តុះបណ្តាល៖ ការណែនាំ និងទិដ្ឋភាពទូទៅ**<br>- សុន្ទរកថាផ្តើមដោយទីប្រឹក្សាបច្ចេកទេស TBDIAH (៥នាទី)<br>- សុន្ទរកថាកិច្ចបើកដោយប្រធានមជ្ឈមណ្ឌលជាតិកំចាត់រោគរបេង និងហង់សិន (៥នាទី) | **Dr. Kai-Lih Liu (ខៃលី)**<br>**វេជ្ជ. ហួត ចាន់យុដា** |
| ៩:១៥–៩:២៥ | ថតរូបអនុស្សាវរីយ៍ជុំគ្នា | |
| ៩:២៥–៩:៤៥ | សម្រាកអាហារសម្រន់ | ទាំងអស់គ្នា |
| ៩:៤៥–១០:០០ | តេស្តមុនវគ្គ | **អ្នកបណ្តុះបណ្តាល**<br>**Dr. Kai-Lih Liu** |
| ១០:០០–១២:០០ | **វគ្គទី១៖ សេចក្តីផ្តើមពីការសិក្សាស្រាវជ្រាវបែបបរិមាណ**<br>- គោលបំណងនៃការសិក្សាស្រាវជ្រាវបែបបរិមាណវិស័យ<br>- ឧទាហរណ៍ពីការស្រាវជ្រាវបែបបរិមាណវិស័យ<br>- ភាពខុសគ្នានៃការសិក្សាបែបបរិមាណវិស័យ និងគុណវិស័យ<br><br>**វគ្គទី២៖ វិធីសាស្ត្រសិក្សាស្រាវជ្រាវបែបគុណវិស័យ**<br>- ការសម្ភាសបែបស៊ីជម្រៅ (IDI) | **អ្នកបណ្តុះបណ្តាល**<br>លោក មាន ឈាន<br>វេជ្ជ. យុន គីមអ៊ាម<br>**សហ-ក្រុមបណ្តុះបណ្តាល**<br>វេជ្ជ. អាន់ យ៉ុម<br>**Dr. Kai-Lih Liu**<br>លោកស្រី សៅ សារ៉ាឌី |
| ១២:០០-១៣:៣០ | អាហារថ្ងៃត្រង់ | ទាំងអស់គ្នា |
| ១៣:៣០–១៤:៣០ | **វគ្គទី២៖ វិធីសាស្ត្រសិក្សាស្រាវជ្រាវបែបគុណវិស័យ**<br>- ការសម្ភាសបែបក្រុមពិភាក្សាស៊ីជម្រៅ (FGD)<br>- ការអង្កេតលើរចនាសម្ព័ន្ធ<br>- ករណីសិក្សា ឬ ខ្សែជីវិត | **អ្នកបណ្តុះបណ្តាល**<br>លោក មាន ឈាន<br>វេជ្ជ. យុន គីមអ៊ាម<br>**សហ-ក្រុមបណ្តុះបណ្តាល**<br>វេជ្ជ. អាន យ៉ុម<br>**Dr. Kai-Lih Liu**<br>លោកស្រី សៅ សារ៉ាឌី |
| ១៤:៣០–១៤:៥០ | សម្រាកអាហារសម្រន់ | ទាំងអស់គ្នា |
| ១៤:៥០–១៧:០០ | **វគ្គទី២៖ ការគ្រប់គ្រងទិន្នន័យ និងការវិភាគទិន្នន័យបែបគុណវិស័យ**<br>- ខ្សែអាត់សំឡេង និងបំលែកប្រែសំឡេងទៅជាអក្សរ<br>**ការអនុវត្ត១៖ ការបង្កើតការស្រាវជ្រាវបែបគុណវិស័យ** | **អ្នកបណ្តុះបណ្តាល**<br>លោក មាន ឈាន<br>វេជ្ជ. យុន គីមអ៊ាម<br>**សហ-** |

| | | |
|---|---|---|
| | - ការជ្រើសរើសវិធីសាស្ត្រស្រាវជ្រាវ<br>- ការបង្កើតសំណួរស្រាវជ្រាវ | **ក្រុមបណ្តុះបណ្តាល**<br>វេជ្ជ. អាន យ៉ុម<br>**Dr. Kai-Lih Liu**<br>លោកស្រី សៅ សារ៉ាឌី |

| ពេលវេលា | ប្រធានបទ/សកម្មភាព | អ្នកសម្របសម្រួល |
|---|---|---|
| ១០ មីនា ឆ្នាំ២០២៣ (ថ្ងៃទី២) | | |
| ០៨:៣០–១០:៣០ | **ការអនុវត្តទី២៖ ការប្រមូលទិន្នន័យបែបគុណវិស័យ (ទីតាំង)**<br>- ការដឹកនាំធ្វើការស្រាវជ្រាវបែបគុណវិស័យ<br>- ការគ្រប់គ្រងទិន្នន័យ | **ក្រុមបណ្តុះបណ្តាល**<br>លោក មាន ឈាន<br>ជៀន សម្ផស្ស<br>**សហ-អ្នកបណ្តុះបណ្តាល**<br>វេជ្ជ. យុន គីមអ៊ាម<br>**Dr.** Kai-Lih Liu<br>លោកស្រី សៅ សារ៉ាឌី |
| ១០:៣០–១០:៥០ | សម្រាកអាហារសម្រន់ | ទាំងអស់គ្នា |
| ១០:៥០–១២:០០ | ***វគ្គទី៣៖*** **ការគ្រប់គ្រងទិន្នន័យបែបគុណវិស័យ និងការវិភាគទិន្នន័យ**<br>- ការគ្រប់គ្រងទិន្នន័យតាមគោលដៅ<br>- ការវិភាគទិន្នន័យដោយកម្មវិធីអ៊ិនវីវ៉ូ(Nvivo) | **ក្រុមបណ្តុះបណ្តាល**<br>លោក មាន ឈាន<br>ជៀន សម្ផស្ស<br>**សហ-អ្នកបណ្តុះបណ្តាល**<br>វេជ្ជ. យុន គីមអ៊ាម<br>វេជ្ជ. អាន យ៉ុម<br>**Dr. Kai-Lih Liu** |
| ១២:០០-១៣:៣០ | អាហារថ្ងៃត្រង់ | ទាំងអស់គ្នា |
| ១៣:៣០–១៦:២០ | **ការអនុវត្តទី៣៖ ការគ្រប់គ្រងទិន្នន័យបែបគុណវិស័យ និងការវិភាគទិន្នន័យ**<br>- អនុវត្តន៍ការវិភាគទិន្នន័យ<br>- ការបង្ហាញលទ្ធផលនៃការស្រាវជ្រាវ | **ក្រុមបណ្តុះបណ្តាល**<br>លោក មាន ឈាន<br>ជៀន សម្ផស្ស<br>**សហ-អ្នកបណ្តុះបណ្តាល**<br>វេជ្ជ. យុន គីមអ៊ាម<br>វេជ្ជ. អាន យ៉ុម<br>**Dr. Kai-Lih Liu** |
| ១៦:២០–១៦:៣០ | សម្រាកអាហារសម្រន់ | ទាំងអស់គ្នា |
| ១៦:៣០-១៧:០០ | តេស្តក្រោយវគ្គ និងបិទវគ្គសិក្ខាសាលា | **ក្រុមបណ្តុះបណ្តាល**<br>ជៀន សម្ផស្ស<br>**Dr. Kai-Lih Liu** |

## សមាជិកក្រុមបណ្តុះបណ្តាល

- **Dr. Kai-Lih Liu (ខៃលី)** ទីប្រឹក្សាបច្ចេកទេសការពង្រឹងសមត្ថភាពការស្រាវជ្រាវជំងឺរបេង TB DIAH
- លោក **មាន ឈាន** ប្រធានក្រុមដឹកនាការងារ TB DIAH កម្ពុជា

- វេជ្ជ. **អាន យ៉ុម**
  ទីប្រឹក្សាបច្ចេកទេសនៃទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ USAID STAR
- វេជ្ជ. **ឃុន គឹមអ៊ាម** អនុប្រធានមជ្ឈមណ្ឌលជាតិកំចាត់រោគរបេង និងហង់សិន CENAT
- លោក **ជៀន សម្ផស្ស** គ្រូបង្រៀននៅវិទ្យាស្ថានជាតិសុខភាពសាធារណៈ NIPH
- លោកស្រី **សៅ សារ៉ាឌី** ទីប្រឹក្សាបច្ចេកទេស TBDIAH

## ខ្លឹមសារនៃកម្មវិធីសិក្សា

**សេចក្តីផ្តើមនៃការសិក្សាស្រាវជ្រាវបែបគុណវិស័យវិស័យ**




**រូបទី២. សេចក្តីផ្តើមនៃការស្រាវស្រាវបែបគុណវិស័យ**

ជាដំបូង យើងគួរតែណែនាំពីគោលគំនិត និងគោលបំណងជាមូលដ្ឋាននៃការស្រាវជ្រាវបែបគុណវិស័យនេះ។




**រូបទី៣. សេចក្តីផ្តើមនៃការសិក្សាស្រាវជ្រាវបែបគុណវិស័យ**

- ការស្រាវជ្រាវបែបគុណវិស័យត្រូវបានអនុវត្តដើម្បីស្វែងរកកត្តា "ហេតុអ្វី" និង "របៀប" នៅក្នុងសំណួរស្រាវជ្រាវរបស់អ្នក។
- វាគឺជាការស្វែងរក និងមិនមែនបរិយាយអំពីតួរលេខនោះទេ ជំនួសវិញដោយផ្តោតលើ**ហេតុផល ការលើកទឹកចិត្ត អាកប្បកិរិយា** និង**គំនិត** ក្នុងសំណួរស្រាវជ្រាវរបស់អ្នក។
- វាល្អបំផុតក្នុងការជួយអ្នកឱ្យទទួលបាន**ការយល់ដឹង** និងស្វែងយល់**ស៊ីជម្រៅ**ទៅក្នុងបញ្ហាជាក់លាក់ណាមួយ។
- ប្រភេទនៃទិន្នន័យនេះជាធម្មតាបានមកពីការសន្ទនា ការសម្ភាស និងការឆ្លើយតបទៅនឹងសំណួរបើក។

សម្រាប់ការស្រាវស្រាវបែបគុណវិស័យ

- វាមានភាពបត់បែន
- វាបង្កើតបានជាសំណុំទិន្នន័យយ៉ាងសម្បូរបែប
- វាបានរួមបញ្ចូលទាំងវិធីសាស្ត្រផ្សេងៗគ្នាមួយចំនួនថែមទៀត
- វាបានពិចារណាទៅលើទស្សនៈ និងការរំពឹងទុកផ្សេងៗរបស់អ្នកស្រាវជ្រាវពេញមួយដំណើរការតែម្តង
- វាបានពិចារណាទៅលើលើទស្សនៈ និងការរំពឹងផ្សេងៗទុករបស់អ្នកចូលរួមពេញមួយដំណើរការតែម្តង

**លក្ខណៈ ៥ យ៉ាងនៃការសិក្សាបែបគុណវិស័យ**

១. ការកំណត់ជាធម្មតាគឺជាប្រភពផ្ទាល់នៃទិន្នន័យ ហើយការស្រាវជ្រាវគឺជាឧបករណ៍ដ៏សំខាន់ក្នុងការ

ស្រាវជ្រាវបែបគុណវិស័យនេះ។

២. ទិន្នន័យស្រាវជ្រាវបែបគុណវិស័យត្រូវបានប្រមូលក្នុងជាទម្រង់ជាពាក្យ ជារូបភាព រូបថត ឬវីដេអូ ជាដើម

៣. អ្នកស្រាវជ្រាវបែបគុណវិស័យមានការព្រួយបារម្ភជាមួយនឹងដំណើរការ ក៏ដូចជាផលិតផល នៃដំណើរការ

ផងដែរ។

៤. អ្នកស្រាវជ្រាវបែបគុណវិស័យមានទំនោរវិភាគទិន្នន័យរបស់ពួកគេដោយប្រយោល ពួកគេមានទំនោរដូចជា

" ធ្វើវាទៅតាមដំណើរ "ការបង្កើតទ្រឹស្តី គំនិត និងសម្មតិកម្ម នៅពេលដែលការស្រាវជ្រាវនៅតែបន្តទៅទៀត។

៥. កង្វល់ចម្បងនៃការស្រាវជ្រាវបែបគុណវិស័យគឺនៅក្នុងរបៀបដែលមនុស្សយល់អំពីស្ថានភាពជីវិតរបស់ពួក

គេយ៉ាងដូចម្តេច។




**រូបទី៤. តើអ្វីទៅជាការស្រាវជ្រាវបែបគុណវិស័យ**

រាល់បញ្ហាសុខភាពគឺមានលក្ខណៈស្មុគស្មាញ មិនត្រឹមតែកត្តាសរីរសាស្ត្រ ឬជីវសាស្ត្រប៉ុណ្ណោះទេ ថែមទាំងផ្នែកផ្លូវចិត្ត និងវប្បធម៌ទៀតផង។ ការស្រាវជ្រាវបែបគុណវិស័យ គឺសំខាន់ត្រូវស្វែងរកពីបញ្ហាសុខភាពដោយធ្វើបញ្ជាក់ពីទំនាក់ទំនងដូចខាងក្រោម៖

១. អត្ថន័យផ្ទាល់ខ្លួន និងសង្គម

២. ការអនុវត្តរបស់បុគ្គល និងវប្បធម៌

៣. បរិបទ ឬបរិដ្ឋាននៃសម្ភារៈ




**រូបទី៥. គោលបំណងនៃការស្រាវជ្រាវបែបគុណវិស័យ**

**គោលបំណងនៃការស្រាវជ្រាវបែបគុណវិស័យមានដូចជា៖**

១. ពិនិត្យមើលពីបាតុភូត ឬបញ្ហាដែលស្មុគស្មាញ

២. ស្វែងយល់ពីប្រធានបទស្រាវជ្រាវដោយប្រើវិធីសាស្ត្របែបស៊ីជម្រៅ

៣. ពិពណ៌នាអំពីបទពិសោធន៍របស់មនុស្សអំពីបញ្ហាសុខភាពជាក់លាក់ណាមួយ

៤.
ស្វែងរកព័ត៌មានចម្បងៗបន្ថែមទៀតលើរបកគំហើញនៃការស្រាវជ្រាវបែបបរិមាណវិស័យដែលបានធ្វើកន្លងមក




**រូបទី៦. ភាពខុសគ្នារវាងការស្រាវជ្រាវបែបគុណវិស័យ និងបែបបរិមាណវិស័យ (១)**

ខណៈពេលដែលការស្រាវជ្រាវបែបបរិមាណវិស័យ ផ្តោតលើចំនួនលេខ អត្រាភាគរយ និងភាពខ្លាំងនៃទំនាក់ទំនង តែការស្រាវជ្រាវបែបគុណវិស័យវិញគឺធ្វើឡើងដើម្បីស្វែងរកព័ត៌មានផ្ទាល់ខ្លួនយ៉ាងស៊ីជម្រៅ បរិបទវប្បធម៌ ឬសង្គម និងគំនិតថ្មីៗ។

ការស្រាវជ្រាវបែបបរិមាណវិស័យគឺដឹកមុខដោយការប្រើប្រាស់ទិន្នន័យដែលមានគោលបំណង(ទិន្នន័យដែលជំរុញដោយមានគោលបំណង) និងព័ត៌មានជាលេខជាក់ស្តែង ដើម្បីឆ្លើយនូវសំណួរស្រាវជ្រាវអំពី "ចំនួនប៉ុន្មាន" ឬ "ប៉ុន្មាន" ដោយមានភាពខុសគ្នា និងការផ្លាស់ប្តូរដែលទាក់ទងនឹងបញ្ហាសុខភាព។

ទោះជាយ៉ាងណា ការស្រាវជ្រាវបែបគុណវិស័យ  គឺជាការបង្កើតនូវដំណើរការនៃការគិតគូរមួយ ជាមួយនឹងសម្រង់ពីលទ្ធផលនៃការសម្ភាសដើម្បីបង្ហាញព័ត៌មានសារបានជាក់លាក់ក្នុងហេតុផល "ហេតុអ្វី" តើអ្វី "ឬ" របៀបណា" ហេតុផល និងឥទ្ធិពលទាំងឡាយដែលទាក់ទងនឹងបញ្ហាសុខភាព។

## ការសិក្សាស្រាវជ្រាវតាមបែបគុណវិស័យ

ភាពខុសគ្នារវាងការស្រាវជ្រាវតាមបែបគុណភាព និងបរិមាណវិស័យ

**Types of Empirical Research**

| | Qualitative Research | Quantitative Research |
|---|---|---|
| **Objective** | • Gain an understanding of underlying reasons or motivations.<br>• Uncover trends or provide insights into the setting of a problem. | • Quantify data and generalize results from a sample from the population of interest.<br>• Measure the incidence of a particular occurrence, view or opinion in a chosen sample. |
| **Sample** | Usually a small number of non-representative cases. Subjects can be chosen deliberately to text a particular theoretical premise. | Usually a large number of subjects who are randomly selected and represent the population of interest. |
| **Data Analysis** | Non-statistical; data cannot be expressed as a number. | Statistical; data can be expressed as a number. |
| **Example** | Temperature: “cold”<br>Height: “tall” | Temperature: 9° Fahrenheit<br>Height: 6’8” |

https://libguides.lib.rochester.edu/c.php?g=472552&p=3237208

**រូបទី៧. ភាពខុសគ្នារវាងការស្រាវជ្រាវបែបគុណវិស័យ និងបរិមាណវិស័យ(២)**

ភាពខុសគ្នារវាងការស្រាវជ្រាវបែបគុណវិស័យ និងបរិមាណវិស័យមានពិពណ៌នាដូចខាងក្រោមៈ

| | **ការស្រាវជ្រាវបែបគុណវិស័យ** | **ការស្រាវជ្រាវបែបបរិមាណវិស័យ** |
|---|---|---|
| **គោលបំណង** | - ទទួលបានការយល់ដឹងអំពីហេតុផលដែលសំខាន់ ឬការជំរុញលើកទឹកចិត្ត<br>- បង្ហាញពីនិន្នាការ ឬផ្តល់ការយល់ដឹងអំពីការកំណត់នូវបញ្ហាស្រាវជ្រាវ | - បរិមាណទិន្នន័យ និងបកស្រាយលទ្ធផលជាទូទៅចេញសំណាកមួយ ដល់ក្រុមប្រជាជនគម្រូ ឬប្រជាជននៃក្រុមគោលដៅ<br>- វាស់វែងអត្រាអាំងស៊ីដង់ ឬអត្រាប្រេវ៉ាឡង់នៃជំងឺជាក់លាក់មួយដែលមានកត្តាហានិភ័យ ឬគំនិតក្នុងការជ្រើសរើសគម្រូតាង |
| **សំណាក** | - ជាទូទៅមានចំនួនតូចតួចនៃករណីដែលមិនតំណាងជាទូទៅបានទេ<br>- ប្រធានបទអាចជ្រើសរើសដោយចេតនាដើម្បីសរសេរអត្ថបទទ្រឹស្តីជាក់លាក់ណាមួយ | - ជាទូទៅ ទិន្នន័យមានទំហំធំ យើងត្រូវធ្វើការជ្រើសរើសគម្រូតាងដោយចៃដន្យ ហើយវានឹងតំណាងឱ្យចំនួនប្រជាជនសំណាកនោះ។ |
| **ការវិភាគទិន្នន័យ** | - មិនមានការវិភាគជាស្ថិតិទេ<br>- ទិន្នន័យមិនអាចបង្ហាញលេខបានទេ | - ការវិភាគជាស្ថិតិលេខ<br>- ទិន្នន័យអាចបង្ហាញជាលេខឬ ភាគរយ |
| **ឧទាហរណ៍** | - សីតុណ្ហភាព: "ត្រជាក់" "ក្តៅ"<br>- កម្ពស់: "ខ្ពស់" ខ្លី/ទាប "<br>- ទម្ងន់៖ "ធាត់" "ស្តើង/ស្គម" | - សីតុណ្ហភាព: ៣០អង្សាសេ<br>- កម្ពស់: ១៧០ សង់ទីម៉ែត្រ<br>- ទម្ងន់៖ ៨០ គីឡូក្រាម |




**រូបទី៨. ភាពខុសគ្នារវាងការស្រាវជ្រាវបែបគុណវិស័យ និងបរិមាណវិស័យ(៣)**

ការស្រាវជ្រាវបែបបរិមាណវិស័យ គឺប្រើកម្រងសំណួរសម្រាប់តាមដានទិន្នន័យ, ការស្ទង់មតិ,ទិន្នន័យដែលប្រើរួច, ឬម៉ូដែលស្ថិតិ ដើម្បីស្វែងរកពីកត្តា 'អ្វី' នៅក្នុងបញ្ហាសុខភាព។ ចំណែកការស្រាវជ្រាវបែបគុណវិស័យវិញ គឺជាអង្កេតលើកត្តា "ហេតុអ្វី" ដោយអង្កេតលើអ្នកចូលរួមផ្ទាល់, ឯកសារកត់ត្រា, កំណត់ត្រាសំឡេងថតពេលសម្ភាស និងទម្រង់សំណួរបើក។ ទោះយ៉ាងណាយើងអាចរួមបញ្ចូលគ្នានូវវិធីសាស្ត្រស្រាវជ្រាវទាំងពីរនេះក្នុងការអង្កេតពី "តើអ្វី"និង "ហេតុអ្វី" ពីបញ្ហាសុខភាព។




**រូបទី៩. វិធីសាស្ត្រចម្រុះ៖ ការស្រាវជ្រាវបែបគុណវិស័យ និងបរិមាណវិស័យ**

ផ្អែកលើមូលដ្ឋានលើឯកសារកាលប្បវត្តិនៃការស្រាវជ្រាវបែបគុណវិស័យ និងបរិមាណវិស័យ ការស្រាវជ្រាវចម្រុះនេះរួមមានគោលបំណងស្រាវជ្រាវចំនួន៣ផ្សេងៗគ្នា៖

១. ការប្រើប្រាស់លទ្ធផលនៃការសិក្សាបែបគុណវិស័យដើម្បីបង្កើតឧបករណ៍ស្រាវជ្រាវថ្មីមួយសម្រាប់ការស្រាវជ្រាវបែបបរិមាណវិស័យ៖ គឺគេធ្វើការសិក្សាបែបគុណវិស័យមុន បន្ទាប់មកទៀតធ្វើការសិក្សាបែបបរិមាណវិស័យតាមក្រោយ។

២. កំណត់ពីរបកគំហើញអ្វីចេញពីការសិក្សាបែបបរិមាណវិស័យនោះដែលត្រូវការពន្យល់លម្អិតបន្ថែមទៀត៖ ការស្រាវជ្រាវបែបបរិមាណវិស័យ ត្រូវបានធ្វើឡើងមុនពេលការស្រាវជ្រាវបែបគុណវិស័យ។

៣. ពិភាក្សាអំពីភាពស្រដៀងគ្នា និងភាពខុសគ្នារវាងលទ្ធផលនៃការសិក្សាស្រាវជ្រាវបែបគុណវិស័យ និងបែបបរិមាណវិស័យ៖ វិធីស្រាវជ្រាវទាំងពីរត្រូវបានធ្វើឡើងស្របគ្នាក្នុងគោលបំណងដើម្បីធ្វើការប្រៀបធៀប។

**តើអ្វីទៅជាគុណសម្បត្តិនៃការស្រាវជ្រាវបែបគុណវិស័យ?**

- **នាំអ្នកស្រាវជ្រាវឱ្យខិតទៅជិតបទពិសោធន៍របស់មនុស្ស៖**
    - ដាក់បទពិសោធន៍ក្នុងបរិបទជាធំ
    - អ្នកឆ្លើយតបក្នុងការផ្តល់ពត៌មានដោយពិពណ៌នាអំពីបទពិសោធន៍របស់ពួកគេរៀបរាប់ពាក្យសម្តីរបស់ពួកគេផ្ទាល់
    - ផ្តល់ឪកាសដល់អ្នកដែលមិនដែលបានបញ្ចេញទស្សនៈ

- **របកគំហើញនៃវិធីសាស្ត្រ**
    - កំណត់ពីគំនិត/ប្រធានបទថ្មីដែលផុសចេញពីទិន្នន័យ

- **មានប្រយោជន៍សម្រាប់ការយល់ដឹងអំពីបាតុភូតស្មុគស្មាញ ជាច្រើនប្រភេទ និងបាតុភូតពហុវិមាត្រ៖**
    - ដំណើរការ និងយន្តការនៃការផ្លាស់ប្តូរ
    - ការកំណត់អត្តសញ្ញាណ និងបញ្ជាក់ការយល់ឃើញរបស់ក្រុមអ្នកពាក់ព័ន្ធផ្សេងៗទៀត
    - តាមដានព្រឹត្តិការណ៍ពិសេសនិងព្រឹត្តិការណ៍ដែលមិនបានរំពឹងទុក




**រូបទី១០. ពាក្យគន្លឹះក្នុងការស្រាវជ្រាវបែបគុណវិស័យ**

ចេញតារាងនៃពាក្យគន្លឹះអំពីការសិក្សាបែបគុណវិស័យ
អ្នកត្រូវពិភាក្សាជាមួយក្រុមក្នុងគម្រោងរបស់អ្នក៖ នៅពេលក្រុមរបស់អ្នក
គ្រោងនឹងធ្វើការស្រាវជ្រាវបែបគុណវិស័យ តើពាក្យគន្លឹះមួយណាដែលសំខាន់ក្នុងរូបភាពនេះ
ដែលវាអាចមានសារៈសំខាន់ក្នុងការបង្កើតពិធីសារស្រាវជ្រាវរបស់អ្នក?
ហេតុអ្វីបានជាពាក្យគន្លឹះដែលបានជ្រើសរើសទាំងនេះមានសារៈសំខាន់សម្រាប់អ្នក?

វិធីសាស្ត្រក្នុងការសិក្សាស្រាវជ្រាវបែបគុណវិស័យ




**រូបទី១១. វិធីសាស្ត្រក្នុងការសិក្សាស្រាវជ្រាវបែបគុណវិស័យ**




**រូបទី១២. ក្របខណ្ឌបញ្ញត្តិនៃការសិក្សាស្រាវជ្រាវបែបគុណវិស័យ**

ក្របខណ្ឌបញ្ញត្តិមួយ គឺមានទ្រឹស្តីផ្លូវការមួយ ឬច្រើន (មួយផ្នែក ឬទាំងមូល) ក៏ដូចជាគោលគំនិតផ្សេងទៀត និងការរកឃើញជាក់ស្តែងចេញពីការរំលឹកទ្រឹស្តី។ គេបានប្រើប្រាស់វាដើម្បីបង្ហាញទំនាក់ទំនងរវាងគំនិតទាំងនេះ និងរបៀបដែលពួកគេជាប់ទាក់ទងទៅនឹងការសិក្សាស្រាវជ្រាវនោះ។

ក្នុងគោលបំណងដើម្បីអភិវឌ្ឍការស្រាវជ្រាវបែបគុណវិស័យដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ អ្នកត្រូវដឹកនាំការស្រាវជ្រាវទៅលើការរំលឹកទ្រឹស្តីនិងបង្កើតក្របខណ្ឌបញ្ញត្តិមួយ។ រូបភាពនេះត្រូវបានដកស្រង់ពីការសិក្សាបែបគុណវិស័យក្នុងការធ្វើរោគវិនិច្ឆ័យជំងឺរបេងនៅក្នុងប្រទេសកេនយ៉ា។ ក្របខណ្ឌនេះបានកំណត់ពីកត្តាបុគ្គល សង្គមវប្បធម៌ និងរចនាសម្ព័ន្ធដែលទាក់ទងជាមួយនឹងការស្វែងរកជំនួយក្នុងការធ្វើរោគវិនិច្ឆ័យជំងឺរបេង។ ក្របខណ្ឌគំនិតនេះអាច យកមកអនុវត្តដើម្បីបង្កើតវិធីសាស្រ្តប្រមូលទិន្នន័យ និងបង្កើតសំណួរស្រាវជ្រាវបាន។




រូបទី១៣. វិធីសាស្ត្រស្រាវជ្រាវបែបគុណវិស័យ

**វិធីសាស្ត្រស្រាវជ្រាវបែបគុណវិស័យរួមមាន៖**

១. ការសម្ភាសស៊ីជម្រៅ (IDI)៖ ដើម្បីកំណត់អត្តសញ្ញាណ "ក្រុមជនបង្គោលសំខាន់ៗ"
២. ការពិភាក្សាជាក្រុម (FGD)៖ ដើម្បីជ្រើសរើសអ្នកចូលរួមចេញពីក្រុមប្រជាជនក្រុមគោលដៅ
៣. ការអង្កេតដោយផ្ទាល់៖ ដើម្បីជ្រើសរើសទីតាំងអង្កេតមើលពីដំណើរការ ឬសក្ដានុពលក្នុងក្រុម
៥. ករណីសិក្សា ឬរឿងរ៉ាវជីវិត៖ ដើម្បីចងក្រង និងបង្ហាញពីករណីពិសេស ឬតំណាងករណីណាមួយ



## រូបទី១៤. វិធីសាស្ត្រស្រាវជ្រាវបែបគុណវិស័យ៖ ការសម្ភាសស៊ីជម្រៅ (IDI)

ការសម្ភាសស៊ីជម្រៅ (IDI) គឺជាការសម្ភាសដែលមិនមានរចនាសម្ព័ន្ធ ដោយប្រើ ទម្រង់សំណួរបើក។ វាមានភាព**បត់បែន**ក្នុងការធ្វើឱ្យអ្នកឆ្លើយសំណួរធ្វើការពិភាក្សានូវគំនិតរបស់ពួកគេ។

ពេលខ្លះ វាត្រូវបានគេហៅថា ការសម្ភាសជនបង្គោល(KII) ដើម្បីស្វែងរកការយល់ដឹងពីភាគីពាក់ព័ន្ធដែលបានជ្រើសរើសក្នុងសំណាក។ ជំនាញសម្ភាស និងជំនាញសម្របសម្រួលមានទំនាក់ទំនងរបស់អ្នកស្រាវជ្រាវគឺមានសារៈសំខាន់ណាស់ក្នុងការប្រមូលទិន្នន័យគុណវិស័យល្អ




**រូបទី១៥. វិធីសាស្ត្រស្រាវជ្រាវបែបគុណវិស័យ៖ ប្រភេទនៃការសម្ភាស**

## ការសម្ភាសបែបគុណវិស័យ មានពីរប្រភេទ រួមមាន៖

(១) ការសម្ភាសដោយគ្មានរចនាសម្ព័ន្ធ និង
(២) ការសម្ភាសបែបពាក់កណ្តាលរចនាសម្ព័ន្ធ
លក្ខណៈមួយចំនួននៃការសម្ភាសត្រូវបានរាយជាបញ្ជីសម្រាប់ជាពត៌មានបន្ថែមដល់អ្នក។

## របៀបសរសេរការណែនាំសម្រាប់ការសម្ភាស

- កំណត់ប្រធានបទសម្ភាស និងសំណួរ
- សម្រេចចិត្តលើកម្រិតនៃព័ត៌មានលម្អិត
- ពង្រាងសំណួរស្រាវជ្រាវ
- ដាក់សំណួរស្រាវជ្រាវតាមលំដាប់លំដោយ
- **វាយបញ្ជីសួរដេញដោល និងជំរុញ**
- សាកល្បងការណែនាំសម្ភាស

## អ្វីជាការសួរសំណួរដេញ?

- គឺជាបច្ចេកទេសដែលប្រើដើម្បីជំរុញអ្នកឆ្លើយតបឱ្យផលិតព័ត៌មានបន្ថែម ដោយមិនចាំបាច់ពន្យល់ពួកគេជាច្រើនដងនោះទេ។

**ឧទាហរណ៍នៃការសួរសំណួរដេញ៖**

- o តើអ្នកអាចពន្យល់ចំណុចនោះ បន្ថែមបន្តិចទៀតបានដែរឬទេ?
- o តើអ្នកអាចផ្តល់ឧទាហរណ៍មួយដល់ខ្ញុំអំពីអ្វីដែលអ្នកចង់និយាយដែរឬទេ?

- តើអ្នកអាចនិយាយបន្ថែមទៀតបានដែរឬទេ?
- សូមពណ៌នាអំពីអ្វីដែលអ្នកចង់លើកមកនិយាយ?
- តើអ្នកធ្លាប់មានបទពិសោធន៍អ្វីខ្លះ ដែលធ្វើឱ្យអ្នកមានអារម្មណ៍បែបនេះ?

## Qualitative Research Methods

### Conversational Probes in In-Depth Interview (IDI)

| | |
|---|---|
| Ask for a story | *"What happened last time you..?"* |
| Explore additional descriptions | *"I'm interested what you described before, could you tell me more?"* |
| Ask for clarification | *"What do you mean by...?"; "In what way?"* |
| Search for opinions | *"What do you think of that?"; "Do you believe that?"* |
| Pursue the logic of an argument | *"Does I follow, then, that...?"* |
| Seek comparisons | *"How does this related to..?";"Some others have said that..."* |
| Check on apparent contradictions, implausibility, exaggerations, or inconsistencies | *"Yes, but didn't you say a month ago..?"*<br>*"How could that be so if..?"*<br>*"Does it necessarily follow that..?"* |
| Express doubts or astonishment | *"Really?"; "After only 6 months?"* |
| Ask hypothetical questions | *"Yes, but what if..?"; "Supposing..?"* |
| Aim for comprehensiveness | *"Have you any other opinions/findings...?"; "Have you anything more to say on that?"* |
| Summarize occasionally and ask for justification | *"What you are saying is..?"; "Would it be correct to say..?"* |

*Source: World Bank Group (2015): Multi-Regional Cost-effectiveness and Qualitative Analysis Tools for RBF Impact Evaluations*

**រូបទី១៦. ការសន្ទនាដេញដោលនៅក្នុងការសម្ភាសបែបស៊ីជម្រៅ (IDI)**

**ការសន្ទនាដេញដោលនៅក្នុងការសម្ភាសបែបស៊ីជម្រៅ (IDI) វាមានប្រយោជន៍សម្រាប់ធ្វើការសម្ភាសដូចជា៖**

- សួររឿងអ្វីមួយ៖ *"តើមានអ្វីកើតឡើងកាលពីមុនដែលអ្នក..?"*
- ស្វែងរកការពិពណ៌នាបន្ថែម៖ *"ខ្ញុំចាប់អារម្មណ៍អ្វីដែលអ្នកបានពិពណ៌នាពីមុន តើអ្នកអាចប្រាប់ខ្ញុំបន្ថែមទៀតបានទេ?"*
- ស្នើរសុំការបញ្ជាក់បន្ថែម៖ *" តើអ្នកចង់មានន័យយ៉ាងដូចម្តេច...?"; "ដោយវិធីណាដែរ?"*
- ស្វែងរកមតិ៖ *"តើអ្នកគិតយ៉ាងណាចំពោះរឿងនោះ?"; "តើអ្នកជឿវាដោយរបៀបណា?"*
- ធ្វើតាមឡូស៊ីកនៃអំណះអំណាង៖ *"តើខ្ញុំធ្វើតាម នោះយ៉ាងដូចម្តេច...?"*
- ស្វែងរកការប្រៀបធៀប៖ *"តើវាទាក់ទងនឹង..?"  "អ្នកផ្សេងទៀតបាននិយាយថាដូចម្តេចខ្លះ..."*
- ពិនិត្យមើលភាពផ្ទុយគ្នាជាក់ស្តែង ភាពមិនទុកចិត្ត ការបំផ្លើសការពិត ឬភាពមិនស៊ីសង្វាក់គ្នា៖ *"បាទ ប៉ុន្តែអ្នកមិនបាននិយាយដូច្នេះកាលពីមួយខែមុន..?"; "តើវាអាចទៅជាយ៉ាងណាប្រសិនបើ..?"; «តើវាចាំបាច់ធ្វើតាមហ្នឹង..?»*
- បង្ហាញការសង្ស័យ ឬការភ្ញាក់ផ្អើល៖ *"ពិតទេ?" "បន្ទាប់ពី៦ខែកន្លងទៅ?"*
- សួរសំណួរបែបសម្មតិកម្ម៖ *"បាទ ប៉ុន្តែចុះបើ..?"  "ឧបមាថា..?"*
- គោលបំណងសួរទូទៅ ៖ *"តើអ្នកមានគំនិតយោបល់បែបណា/លទ្ធផលបែបណា...?" «តើអ្នកមានអ្វីត្រូវនិយាយបន្ថែមទៀតទេ?»*
- សង្ខេបម្តងម្កាល ហើយសុំបញ្ជាក់ហេតុផល ៖ *"អ្វីដែលអ្នកកំពុងនិយាយគឺ..?"; «តើគួរត្រូវនិយាយ..?»*




**រូបទី១៧. វិធីសាស្ត្រស្រាវជ្រាវបែបគុណវិស័យ៖ ក្រុមពិភាក្សាស៊ីជម្រៅ (FGD)**

- ប្រភេទនៃការសម្ភាសជាក្រុមដែលស្វែងយល់ពីបញ្ហានៃប្រធានបទ
- ជាបែបបទនៃការសម្ភាសគឺដូចជាការធ្វើទំនាក់ទំនងក្នុងចំណោមក្រុមមនុស្ស។
- អ្នកដឹកនាំក្រុម (អ្នកសម្របសម្រួល) នឹងត្រូវស្វែងយល់អំពីប្រធានបទពិសេសណាមួយជាមួយក្រុមដោយសាកសួរសំណួរ, ស្តាប់ចម្លើយដោយយកចិត្តទុកដាក់ និងសួរសំណួរប្រដេញដើម្បីតាមដានរាល់ការឆ្លើយតបរបស់អ្នកឆ្លើយសំណួរ

ក្រុមពិភាក្សាស៊ីជម្រៅ (FGD) គឺជាការពិភាក្សាជាក្រុមដែលប្រើប្រាស់ទម្រង់សំណួរពាក់កណ្តាលរចនាសម្ព័ន្ធ។ វាអាស្រ័យលើការផ្លាស់ប្តូរគំនិត និងយោបល់ក្នុងចំណោមអ្នកចូលរួម។

អ្នកសម្របសម្រួលដើរតួនាទីសំខាន់ជាមគ្គុទ្ទេសដើម្បីជួយសម្រួលដល់ការពិភាក្សាស៊ីជម្រៅជាក្រុម ខណ:ពេលដែលអ្នកកត់ត្រាត្រូវកត់ត្រារាល់ចំណុចផ្សេងៗ និងកំណត់អត្តសញ្ញាណពីការមានប្រតិកម្មពិសេស និងអន្តរបុគ្គលជាក់លាក់ណាមួយក្នុងចំណោមអ្នកចូលរួមក្នុងក្រុមពិភាក្សាស៊ីជម្រៅនេះ។

អ្នកចូលរួមគួរតែមានប្រមាណពី ៨ ទៅ ១០ នាក់ ដែលត្រូវបានជ្រើសរើសឱ្យចូលរួមក្នុងមួយក្រុមពិភាក្សា។ នៅក្នុងវគ្គនីមួយៗនៃក្រុមពិភាក្សាមិនត្រូវធ្វើលើសពីមួយម៉ោងកន្លះនោះទេ។

**តើការប្រើប្រាស់ជាទូទៅនៃក្រុមពិភាក្សាស៊ីជម្រៅផ្តោតលើអ្វីខ្លះ?**

- ស្វែងរកប្រធានបទដែលមានព័ត៌មានតិចតួច
- ការវាយតម្លៃផលិតផលអ្វីមួយ ឬគំនិតផ្សេងៗ
- ការវាយតម្លៃការលើការអន្តរាគមន៍, ការយល់ដឹង, សក្តិសមជាមួយក្រុមគោលដៅ
- ការបញ្ជាក់ និងវាយតម្លៃលទ្ធផលដែលរកឃើញពីការប្រមូលទិន្នន័យ ជាមួយនឹងវិធីសាស្ត្រស្រាវជ្រាវផ្សេងៗទៀត។




**រូបទី១៨. ប្រភេទដែលអ្នកចូលរួមក្នុងការសម្ភាសបែបពិភាក្សាស៊ីជម្រៅ**

សូមប្រយ័ត្នចំពោះអ្នកចូលរួមទាំងដប់ប្រភេទនេះ ដែលបានរកឃើញជាបញ្ហានៅក្នុងការពិភាក្សាជាក្រុមនេះ៖

- **អ្នកដែលប្រញាប់ប្រញាល់:** អ្នកដែលមានភ្នែកម្ខាងសំឡឹងមើលម៉ោង ជានិច្ចកាលគាត់តែងតែព្យាយាមធ្វើអ្វីមួយដោយប្រញាប់ប្រញាល់ឱ្យក្រុមពិភាក្សាប្រព្រឹត្តទៅឆាប់ចប់។
- **អ្នកដែលធ្វើឲ្យគេចាប់អារម្មណ៍**: ក្លែងក្លាយទាំងស្រុង, គ្រាន់តែចូលរួមដើម្បីទទួលបានផលប្រយោជន៍ និយាយមិនសមហេតុសមផល។
- **មនុស្សលេចធ្លោ:** ពួកគេមិនដឹងថាពេលណាដែលពួកគេត្រូវបិទមាត់របស់ពួកគេដោយខ្លួនឯងនោះទេ។
- **មនុស្សចៀម:** ពួកគេតែងតែប្រើប្រាស់គំនិតទៅតាមខ្យល់បក់ មិនមានគំនិតផ្ទាល់ខ្លួនក្នុងការបញ្ចេញមតិនោះទេ
- **អ្នកកំប្លែង:** ពួកគេតែងតែធ្វើឱ្យនណាម្នាក់សើចលេងដោយមិនមានប្រយោជន៍អ្វីឡើយ
- **មនុស្សយន្ត:** ទោះបីជាអ្នកវាយពួកគេ ក៏គេមិនចាប់អារម្មណ៍អ្នកដែរ ពួកគេមិនចង់ចូលរួម និងមិនចង់ចូលរួមក្នុងការពិភាក្សានេះទេ
- **អ្នកគិតដោយសកម្ម:** ធ្វើតាមការពិភាក្សា ចូលរួមយ៉ាងខ្ពស់ និងចូលរួមក្នុងការពិភាក្សា។
- **អ្នកគិតដោយស្ងៀមស្ងាត់:** ពួកគេស្តាប់ដោយការយកចិត្តទុកដាក់ និងគិតគូរមុនពេលពួកគេនិយាយស្តី ប៉ុន្តែពួកគេមិនមែនជាមនុស្សដែលនិយាយច្រើននោះទេ
- **អ្នកបំពាន:** ពួកគេជាមនុស្សដែលអវិជ្ជមាន គម្រាម និងបង្ករលក្ខណៈអសុវត្ថិភាព
- **អ្នកស្វែងរកជំនួយ៖** ពួកគេប្រើប្រាស់ក្រុមពិភាក្សាជាការព្យាបាលចំពោះការមានវិបត្តិផ្ទាល់ខ្លួនរបស់គេ ឬបញ្ហាផ្ទាល់ខ្លួនរបស់ពួកគេ




**រូបទី១៩. វិធីសាស្ត្រស្រាវជ្រាវបែបគុណវិស័យ៖ ការសង្កេតដោយផ្ទាល់(១)**

វាត្រូវបានគេស្គាល់ផងដែរថាជាការសិក្សាដោយអង្កេត ការប្រមូលព័ត៌មានដោយការវាយតម្លៃ ខណៈពេលដែលអ្នកវាយតម្លៃមើលទៅលើវត្ថុបំណងរបស់ពួកគេ ឬនៅក្នុងបរិបទសង្គមបរិស្ថានរបស់គាត់ ។

ការអង្កេតដោយផ្ទាល់ ត្រូវបានប្រើប្រាស់នៅពេលដែលការប្រមូលទិន្នន័យផ្សេងទៀត (ដូចជាការស្ទង់មតិ កម្រងសំណួរ) ដែលមិនមានប្រសិទ្ធភាព។

គោលដៅ គឺដើម្បីវាយតម្លៃដំណើរការអាកប្បកិរិយាដែលកំពុងបន្ត, ព្រឹត្តិការណ៍ ឬស្ថានភាព ឬនៅពេលលទ្ធផល    រូបវន្តដែលអាចមើលឃើញយ៉ាងងាយស្រួល។

**ការសង្កេតដោយផ្ទាល់តាមរចនាសម្ព័ន្ធ** គឺសមស្របបំផុត នៅពេលដែលព័ត៌មានស្តង់ដារត្រូវការប្រមូល និងបណ្តុលឱ្យមានទិន្នន័យជាលក្ខណៈបែបបរិមាណ។ ការសង្កេតដោយផ្ទាល់គ្មានរចនាសម្ព័ន្ធ មើលទៅលើការកើតឡើងជាធម្មជាតិ និងផ្តល់នូវទិន្នន័យបែបគុណវិស័យ។




**រូបទី២០. វិធីសាស្ត្រស្រាវជ្រាវបែបគុណវិស័យៈ ការសង្កេតដោយផ្ទាល់(២)**

ការសង្កេតដោយផ្ទាល់ពីរប្រភេទដែលត្រូវបានអនុវត្តយ៉ាងទូលំទូលាយគឺៈ

**និតិវិធីបែបគ្លីនិកៈ** អ្នកវាយតម្លៃស្ថិតនៅជ្រុងម្ខាង ដើម្បីសង្កេតមើលវិធីសាស្ត្រធ្វើការវិនិច្ឆ័យ និងការព្យាបាលរបស់វេជ្ជបណ្ឌិត ហើយកត់ត្រាក្នុងបញ្ជីត្រួតពិនិត្យដែលមានរចនាសម្ព័ន្ធ ឬទម្រង់ពាក់កណ្តាលរចនាសម្ព័ន្ធ។ ពេលខ្លះការថតវីដេអូអាចត្រូវបានធ្វើឡើងក្នុងនិតិវិធីនេះ។

**នីតិវិធីប្រតិបត្តិៈ** អ្នកវាយតម្លៃស្ថិតនៅជ្រុងម្ខាង ដើម្បីសង្កេតមើលអ្នកបច្ចេកទេសវេជ្ជសាស្ត្រកំពុងដំណើរការប្រើប្រាស់ម៉ាស៊ីនធ្វើរោគវិនិច្ឆ័យអ្នកជំងឺ ហើយកត់ត្រាទៅក្នុងបញ្ជីត្រួតពិនិត្យដែលមានរចនាសម្ព័ន្ធ ឬទម្រង់ពាក់កណ្តាលរចនាសម្ព័ន្ធ។ ពេលខ្លះការថតវីដេអូអាចត្រូវបានធ្វើឡើងផងដែរ ។

**បញ្ហាសំខាន់មួយនៃការសង្កេតដោយផ្ទាល់គឺ "ឥទ្ធិពលនៃHawthorne"** មានន័យថាមនុស្សតែងតែធ្វើកិច្ចការបានល្អនៅពេលដែលពួកគេត្រូវបានចាប់ផ្តើមធ្វើអង្កេត។

បញ្ហាមួយទៀតគឺភាពលំអៀងរបស់អ្នកអង្កេត ដែលបង្កឡើងដោយកត្តាផ្ទាល់ខ្លួន ឬកត្តាគោលបំណងធ្វើឱ្យប៉ះពាល់ដល់លទ្ធផលវាយតម្លៃ។




**រូបទី២១. វិធីសាស្ត្រស្រាវជ្រាវបែបគុណវិស័យ៖ ករណីសិក្សា ឬខ្សែជីវិត**

ករណីសិក្សា គឺជាការសិក្សាស៊ីជម្រៅអំពីបញ្ហាសុខភាពដែលត្រូវបានស្វែងយល់ តាមរយៈករណីមួយ ឬករណីច្រើននៅក្នុងកន្លែង ឬក្នុងបរិបទណាមួយ។
វាក៏ជាការពិពណ៌នាបែបស៊ីជម្រៅអំពីបទពិសោធន៍របស់មនុស្សនៅលីវ,គ្រួសារមួយ, ក្រុមមួយ, សហគមន៍មួយ ឬអង្គការណាមួយ។

ឧទាហរណ៍នៃករណីសិក្សាបែបគុណវិស័យលើប្រវត្តិជីវិត ដែលជារឿងរបស់មនុស្សជាក់លាក់មួយ។

ករណីសិក្សាមួយ អាចត្រូវបានធ្វើឡើងដើម្បីរំលេចពីបញ្ហាជាក់លាក់ណាមួយ ដោយប្រាប់រឿងរ៉ាវរបស់បុគ្គលម្នាក់ ឬក្រុមណាមួយ។

ជាប្រភពព័ត៌មានជាច្រើនក្នុងការផ្តល់ករណីសិក្សារឿងរ៉ាវដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ

សម្រាប់ករណីសិក្សា ឬរឿងរ៉ាវជីវិត ទិន្នន័យត្រូវបានប្រមូលតាមរយៈការសង្កេត ការសម្ភាស និយាយពីប្រវត្តិផ្ទាល់មាត់ និងឯកសារជាដើម។




**រូបទី២២. បច្ចេកទេសជ្រើសរើសសំណាកក្នុងការស្រាវជ្រាវបែបគុណវិស័យ**

៤ ប្រភេទនៃវិធីជ្រើសរើសសំណាក គឺត្រូវបានប្រើប្រាស់ជាទូទៅនៅក្នុងការសិក្សាបែបគុណវិស័យ៖

- ការជ្រើសរើសសំណាកបែបកូតា (Quota)
- ការជ្រើសរើសសំណាកបែបវិនិច្ឆ័យ ឬមានគោលបំណង (Purposive)
- ការជ្រើសរើសសំណាកបែបងាយស្រួល (Convenient)
- ការជ្រើសរើសសំណាកដោយការប្រាប់តគ្នា (Snowball)




**រូបទី ២៣. វិធីសាស្ត្រជ្រើសរើសសំណាកក្នុងការស្រាវជ្រាវបែបគុណវិស័យ**

ខណៈពេលដែល វាមិនចាំបាច់ក្នុងការអនុវត្តការជ្រើសរើសសំណាកបែបប្រូបាប៊ីលីតេ ក្នុងការស្រាវជ្រាវបែបគុណវិស័យនោះ ការជ្រើសរើសសំណាកបែបងាយស្រួល ឬតាមគោលបំណងរបស់អ្នកស្រាវជ្រាវ គឺត្រូវបានប្រើប្រាស់ច្រើនបំផុត។ ការជ្រើសរើសសំណាករួមមានៈ

- ករណីមិនប្រក្រតី ឬហួសកម្រិត
- បម្រែបម្រួលជាអតិបរិមា តាមដែលអាចធ្វើទៅបាន
- សំណាកដែលមានលក្ខណៈប្រហាក់ប្រហែល (មិនចម្រុះ)
- សំណាកដែលមានសារៈសំខាន់ខាងនយោបាយ ឬសង្គម ដូចជាអ្នកផ្តល់ព័ត៌មានសំខាន់ៗ
- ការជ្រើសរើសសំណាកតាមការប្រាប់តគ្នា




**រូបទី ២៤. ឧទាហរណ៍នៃការស្រាវជ្រាវបែបគុណវិស័យ**

ខាងក្រោមនេះ ជាឧទាហរណ៍មួយនៃការរកឃើញនៅក្នុងការស្រាវជ្រាវបែបគុណវិស័យចេញពីការសិក្សាអំពីការធ្វើរោគវិនិច្ឆ័យជំងឺរបេងនៅក្នុងប្រទេសកេនយ៉ា។

ការឆ្លើយតបភាគច្រើន អាចត្រូវបានសង្ខេបទៅជាសេចក្តីថ្លែងការណ៍ទូទៅមួយ ឬច្រើន ដោយសង្កត់ធ្ងន់ទៅលើមតិដែលបានបង្ហាញជាញឹកញាប់បំផុត។ ភាគរយត្រូវបានគេគណនា ដើម្បីបង្ហាញសមាមាត្រនៃមតិសំខាន់មួយក្នុងចំណោមអ្នកចូលរួមនៅក្នុងករណីមួយចំនួនផងដែរ។ សម្រង់ពាក្យពេចន៍ដែលបានមកពីពាក្យដើមរបស់អ្នកចូលរួមម្នាក់ អាចត្រូវបានប្រើដើម្បីបញ្ជាក់ពីសារៈសំខាន់នៃគំនិត ឬអាកប្បកិរិយាមួយ។

ការគ្រប់គ្រងទិន្នន័យ និងការវិភាគទិន្នន័យបែបគុណវិស័យ




**រូបទី២៥. ការគ្រប់គ្រងទិន្នន័យ និងការវិភាគទិន្នន័យបែបគុណវិស័យ**




**រូបទី២៦. ការគ្រប់គ្រងទិន្នន័យនៅក្នុងការសិក្សាស្រាវជ្រាវបែបគុណវិស័យ ៖ ការរក្សាកំណត់ត្រាសំឡេងថត**

**តើការវិភាគជាអ្វី?**

- គឺជាការស្វែងរកគំរូនៅក្នុងទិន្នន័យ និងសម្រាប់គំនិតដែលជួយពន្យល់ពីមូលហេតុដែលគំរូទាំងនោះចាប់ផ្តើមពីដំបូង។
- វត្ថុបំណងនៅក្នុងការស្រាវជ្រាវតាមបែបគុណវិស័យ គឺជាប្រធានបទដែលវិភាគតាមបែបគុណវិស័យ វាជាការបកស្រាយលើប្រធានបទ។ អ្នកស្រាវជ្រាវកំពុងនាំយកអត្ថន័យនៃការវិភាគរបស់ពួកគេទៅធ្វើការវិភាគ និងបកស្រាយពីទិន្នន័យទាំងនោះ។
- ការវិភាគចាប់ផ្តើមជាមួយនឹងទិន្នន័យដែលប្រមូលបានលើកដំបូងនោះ។
- ការវិភាគគឺបន្តពេញគម្រោងស្រាវជ្រាវតែម្តង

កំឡុងពេលប្រមូលទិន្នន័យនៃការសិក្សាបែបគុណវិស័យ ទម្រង់ជាច្រើននៃកំណត់ត្រាសំឡេងថតត្រូវបានរក្សាទុកយ៉ាងប្រុងប្រយ័ត្ន រួមទាំង៖

- កម្រងសំណួរពាក់កណ្តាលរចនាសម្ព័ន្ធនៅក្នុងការសម្ភាសស៊ីជម្រៅ
- ការកត់ត្រានៅក្នុងការសម្ភាសស៊ីជម្រៅ ការសម្ភាសបែបពិភាក្សា និងករណីសិក្សា
- បញ្ជីត្រួតពិនិត្យ និងបញ្ជីសារពើភណ្ឌនៅក្នុងការសង្កេតផ្ទាល់
- ការរក្សាកំណត់ហេតុប្រចាំថ្ងៃក្នុងករណីសិក្សា
- ការថតសំឡេងឌីជីថលនៅក្នុងការសម្ភាសស៊ីជម្រៅ បែបពិភាក្សា និងករណីសិក្សា
- ការថតវីដេអូក្នុងការសម្ភាសបែបស៊ីជម្រៅ ការសង្កេតផ្ទាល់ និងករណីសិក្សា




**រូបទី២៧៖ ប្រតិចារឹកទិន្នន័យបែបគុណវិស័យ**

អ្នកស្រាវជ្រាវបែបគុណវិស័យ ចាប់អារម្មណ៍ក្នុងការសិក្សាអំពីគំនិតរបស់មនុស្ស និងថាមូលហេតុអ្វីបានជាពួកគេមានអាកប្បកិរិយាជាក់លាក់។ ពួកគេអាចថតវីដេអូ ឬអូឌីយ៉ូ ដើម្បីចាប់យក និងរក្សាទុកទិន្នន័យលទ្ធផលទាំងនោះ។ ការសម្គាស និងព្រឹត្តិការណ៍ទាំងនេះបង្កើតបានជាទិន្នន័យដែលមានសារៈសំខាន់។ ទោះជាយ៉ាងណាក៏ដោយ ទិន្នន័យដែលមិនមានរចនាសម្ព័ន្ធត្រូវតែរក្សាទុក និងរៀបចំឱ្យហើយ មុនពេលអ្នកស្រាវជ្រាវចុះធ្វើសកម្មភាពស្រាវជ្រាវ។

នេះគឺជាចំណុចដែលប្រតិចារឹកទិន្ន័យបែបគុណវិស័យមានសារៈសំខាន់ខ្លាំង។ ប្រតិចារឹកបំប្លែងសំឡេងដើមទៅជាអត្ថបទគឺជាការសរសេរអត្ថបទពីអ្វីដែលយើងបានថតអូឌីយ៉ូ ឬវីដេអូទៅជាកំណែអត្ថបទអក្សរ។ ប្រតិចារឹកទិន្នន័យបែបគុណវិស័យ គឺជាចំណុចចាប់ផ្ដើមដ៏ល្អបំផុតមួយ សម្រាប់រៀបចំ និងវិភាគទិន្ន័យរបស់អ្នក។

**ប្រតិចារឹកគឺចាំបាច់សម្រាប់ការស្រាវជ្រាវបែបគុណវិស័យព្រោះវា៖**

- បំប្លែងទិន្នន័យពត៍មានបែបគុណវិស័យទៅជាជាទម្រង់អត្ថបទគោល
- ធ្វើឱ្យទិន្នន័យងាយស្រួលក្នុងការវិភាគ និងចែករំលែកលទ្ធផលស្រាវជ្រាវ
- អនុញ្ញាតឱ្យអ្នកស្រាវជ្រាវវិភាគកាន់តែស៊ីជម្រៅក្នុងទិន្នន័យដែលពួកគេប្រមូលបាន
- អនុញ្ញាតឱ្យអ្នកស្រាវជ្រាវបង្កើតបាននូវពណ៌នារឿងរ៉ាវនៃការស្រាវជ្រាវជាមួយនឹងទិន្នន័យរបស់ពួកគេ
- ធ្វើឱ្យគំរូងាយស្រួលក្នុងការស្វែងរក
- ជួយរក្សាបាននូវភាពត្រឹមត្រូវ និងសុចរិតភាពនៃទិន្នន័យ

បន្ទាប់ពីទិន្នន័យត្រូវបានចម្លងជាទម្រង់អត្ថបទ វាអាចត្រូវបានបញ្ចូលទៅក្នុងសៀវភៅបញ្ជីឬប្រភេទឯកសារស្រដៀងគ្នា ឬវាអាចត្រូវបានបញ្ចូលទៅក្នុងឧបករណ៍វិភាគទិន្នន័យបែបគុណវិស័យតែម្តង។




**រូបទី២៨. ការគ្រប់គ្រងទិន្នន័យស្រាវជ្រាវបែបគុណវិស័យ៖ កំណត់ត្រាពីការចុះប្រមូលទិន្នន័យតាមតំបន់គោលដៅ និងការអង្កេត**

## ស្វែងរកផ្ទៃនៃការសិក្សា និង លំនាំឬគម្រូ

- តើអ្វីជាផ្ទៃឬលំនាំគម្រូគឺជាអ្វី?
    - ជាការបង្ហាញ ឬសម្តែងនូវអ្វីមួយ
- តើធ្វើម៉េចបានដឹងថាអ្នកបានរកឃើញផ្ទៃលំនាំមួយ?
    - “តើការសម្តែងនេះជាឧទាហរណ៍មួយអំពីអ្វីដែរ?”
- តើយើងអាចកំណត់ពីផ្ទៃលំនាំ ដែលសំខាន់បានយ៉ាងដូចម្តេច?
    - តើវាលេចឡើងញឹកញាប់ប៉ុណ្ណា
    - តើវារីករាលដាលពាសពេញតាមប្រភេទផ្សេងៗនៃគំនិតវប្បធម៌ និងការអនុវត្តយ៉ាងម៉េច
    - តើមនុស្សមានប្រតិកម្មយ៉ាងម៉េច ពេលដែលផ្ទៃនេះត្រូវបានគេបំពាន

## អ្វីដែលត្រូវរកមើល

- កំណត់ពាក្យដែលប្រើញឹកញាប់
- ស្វែងរកឃ្លា ឬកថាខណ្ឌដែលមានតិចតួច
- កំណត់ពាក្យប្រៀបធៀប ភាពស្រដៀងគ្នា និងដូចគ្នា
- ស្រដៀងគ្នាទៅនឹងឧទាហរណ៍មុនៗដោយប្រៀបធៀប និងផ្ទុយមកវិញ
- តើអ្វីមិនត្រូវបាននិយាយទាក់ទងនិងទិន្នន័យដែលបាត់?
    - តើប្រធានបទអ្វីខ្លះដែលត្រូវបានជៀសវាង?
    - ប្រធានបទអ្វីដែលបានសន្មត់រួច ហើយមិនបានលើកឡើង

## អ្វីដែលត្រូវធ្វើ (ដំណើរការបច្ចេកទេស)

- ការកាត់ & តម្រៀប៖ កាត់សម្រង់សម្រាប់ផ្ទៃមួយ ហើយប្រើការតម្រៀបគំនរដើម្បីកំណត់អត្តសញ្ញាណផ្ទៃរង ដែលត្រូវបានគេស្គាល់ផងដែរថាជា (ក្រញ៉ាំ និងចាប់ភ្ជាប់)

- បញ្ជីពាក្យ & ពាក្យគន្លឹះក្នុងបរិបទ៖ បង្រួមអត្ថបទចុះក្រោមទៅជាពាក្យ ឬកម្រៀបពាក្យជាក់លាក់ក្នុង

  បរិបទនោះ

**ការកំណត់កូដទិន្នន័យ**

- ការកំណត់កូដ គឺធ្វើនៅពេលដែលយើងបង្កើតទម្រង់ ដើម្បីរៀបចំទិន្នន័យក្នុងការរៀបចំសម្រាប់ ការធ្វើ វិភាគ។
- ឯកសារសម្រាប់សរសេរកូដ គឺគ្រាន់តែជាទម្រង់មួយ ដែលបង្កើតឡើងដោយអ្នកស្រាវជ្រាវ ដើម្បីជួយក្នុងការបែងចែកប្រភេទនិងការរៀបរាប់អំពីឥរិយាបទ
- គ្រោងសរសេរកូដគឺជាការកំណត់អត្ថសញ្ញាណ នៃអាកប្បកិរិយាណាដែលពាក់ព័ន្ធទៅនឹងសំណួរស្រាវជ្រាវ និងរបៀបដែលពួកវានឹងត្រូវបានកត់ត្រា។

**កូដ, ការសរសេរកូដ និងការដាក់កូដ**

- កូដគឺជាសញ្ញាសម្គាល់ខ្លីសម្រាប់គម្រូនៃផ្ទៃ
- ការសរសេរកូដគឺជាបញ្ជីដែលបានរៀបចំសម្រាប់ផ្ទៃនៃកូដ
- កូដគឺជាសកម្មភាពនៃការភ្ជាប់ផ្ទៃជាមួយបំណែកនៃទិន្នន័យបែបគុណវិស័យ

**ប្រភេទនៃកូដ**

- រចនាសម្ព័ន្ធកូដ
  - ពិពណ៌នាអំពីលក្ខណ:នៃទិន្នន័យដោយខ្លួនឯង
  - ឆ្លើយថាអ្នកណា អ្វី កន្លែងណា និងរបៀបដែលទិន្នន័យត្រូវបានប្រមូល
- ផ្ទៃនៃលំនាំរបស់កូដ
  - ភ្ជាប់ផ្ទៃគម្រូលំនាំជាមួយឧទាហរណ៍ជាក់លាក់នៅក្នុងសំណុំទិន្នន័យ
- ការចងចាំ
  - ប្រើដើម្បីកត់ចំណាំទិន្នន័យជាមួយនឹងគំនិតដែលកំពុងដំណើរការរបស់អ្នកអង្កេត
    - គំនិតលម្អិតអំពីលំនាំផ្ទៃ
    - សម្មតិកម្ម ឬទ្រឹស្តីដែលកំពុងលេចចេញមក
    - យោបល់បន្ថែមលើទិន្នន័យខ្លួនឯង




**រូបទី២៩. ការវិភាគទិន្នន័យបែបគុណវិស័យ ដោយប្រើប្រាស់ បញ្ជីកូដទិន្នន័យ គ្រោងកូដទិន្នន័យ**

ការវិភាគទិន្នន័យអនុលោមទៅតាមគ្រោងវិធីបញ្ញត្តិ (Gale et al., ២០១៣)

- បង្កើតតារាងលេខកូដពិពណ៌នាក្របខណ្ឌដោយផ្អែកទៅលើគោលបំណងនៃការសិក្សាស្រាវជ្រាវ និងសំណួរ ហើយនិងលទ្ធផលដំបូងដែលបានពីការកត់ត្រាអំឡុងពេលសម្ភាស, ការអង្កេត និងការសង្ខេបរបស់ក្រុមឡើងវិញ។
- ក្របខណ្ឌវិភាគត្រូវបានកែលម្អបន្ថែមទៀតតាមរយៈការពិភាក្សា និងពិគ្រោះយោបល់ជាមួយក្រុមអ្នកស្រាវជ្រាវ
- អនុវត្តក្របខណ្ឌវិភាគការងារលើបំណកស្រាយសរសេរចេញពីឧបករណ៍ថតសំឡេងដោយបញ្ចូលគ្នាតាមវិធីសាស្ត្រកំណត់លក្ខណៈដោយ ឬផ្អែកលើការសន្និដ្ឋាននៃករណីជាក់លាក់ពីច្បាប់ទូទៅ និងមិនផ្អែកលើច្បាប់ទូទៅ។ នៅក្នុងដំណើរការនេះ វាពាក់ព័ន្ធនឹងការចាត់ជាថ្នាក់ៗនូវរាល់ព័ត៌មានដែលជាអត្ថបទបំប្លែងមកពីសំឡេងថតទៅជាកូដដែលបានកំណត់ជាមុន និងការកត់ត្រា និងរៀបចំកូដថ្មីណាផ្សេងទៀតពីទិន្នន័យនោះ។
- រកមើលលំនាំនៅក្នុងកូដ ដែលត្រូវបានគេហៅថាផ្ទាំងមេ លំនាំនៃអត្ថន័យដដែលៗ គំនិត, ការគិត, អារម្មណ៍។
- អ្នកវិភាគដោយការអាន តាមរយៈអត្ថបទដែលបំប្លែងចេញពីឧបករណ៍សំឡេងនោះ ដោយបន្ថែមកូដថ្មីទៅក្នុងក្របខណ្ឌ និងកែលម្អរចនាសម្ព័ន្ធរបស់វាតាមតម្រូវការ។




**រូបទី៣០. ដំណើរការនៃការវិភាគទិន្នន័យបែបគុណវិស័យ**

## សេចក្តីសម្រង់និងគំនិត

- សំណុំចុងក្រោយនៃផ្ទៃមេ ត្រូវបានសង្ខេបហើយដាក់ចូលទៅក្នុងតារាងអ៊ិចសែល ឬ របនាសម្ព័ន្ធស្រដៀងគ្នា ដែលនៅលើតារាងនេះ ភ័ស្តុតាងដែលបានពីអត្ថបទដើម្បីបម្រុងទុកលើផ្ទៃមេ បង្កើតការសម្រង់អត្ថ ។
- សម្រង់គឺជាពាក្យ និងឃ្លាដែលយកចេញពីអត្ថបទដែលបានបំណកស្រាយជាលាយលក្ខណ៍អក្សរនៃការសម្ភាស គឺដើម្បីបង្ហាញពីគោលគំនិត ឬអត្ថន័យដោយផ្អែកលើការវិភាគ។ ឧទាហរណ៍នៃការភ្ជាប់គំនិតទៅនឹងសម្រង់៖

### គោលគំនិតនៃភាពមានសំណាង (Concept of Luck) “គាក់គប”

*I have a cold hand [Dai Trachek] in raising my pigs. Traditionally people said that a person with cold hands is very Kak Kop [this term can be translated in many meanings], meaning that whatever I do, I succeed. But in fact, it is not true. If a fortune teller says that you have good luck in the future, but if you don't do anything, you will not get anything. So, I have to do everything, learning by doing. I have to try and do it myself because there is no angel to bring you luck if you are not helping yourself. I started with only a few pigs, but now I have more than ten sows. With the recent Pess Afrik [ASF], so many pigs died in the village, wiped out almost all the pigs in this area, except my households, no pigs died during that time"* (ASF_OrdomSoriya_ TramKak_ Takeo_Si_07_M).



Qualitative Data Management & Analysis

Data Analysis with NVivo

- NVivo is a software program used for **qualitative and mixed-methods research**
- NVivo hepls qualitative researchers to organize, analyze and find insights in unstructured or non-numerical data (qualitative data), including:

| Unstructured text | Non-numerical data |
|---|---|
| Audio | Interviews |
| Video | Focus groups |
| Image data | Open-ended surveys |
| | Social media |
| | Journal articles |

- It allows researcher to classify, sort and arrange information; examine relationships in the data; and combine analysis linking, shaping, searching and modeling

**រូបទី៣១. ការវិភាគទិន្នន័យដោយប្រើកម្មវិធីអ៊ិនវីវ៉ូ(១)**

អ៊ិនវីវ៉ូ គឺជាកម្មវិធីដែលប្រើសម្រាប់ការវិភាគទិន្នន័យស្រាវជ្រាវបែបគុណវិស័យ និងវិធីសាស្ត្រស្រាវជ្រាវចម្រុះបែបគុណវិស័យ និងបរិមាណវិស័យ។

អ៊ិនវីវ៉ូ ជួយអ្នកស្រាវជ្រាវក្នុងការរៀបចំការវិភាគបែបគុណវិស័យ ការវិភាគ និងលទ្ធផលបែបស៊ីជម្រៅដែលមិនមានរចនាសម្ព័ន្ធ ឬមិនមែនជាលេខ (ទិន្នន័យបែបគុណវិស័យ) រួមមាន៖

- អត្ថបទមិនមានរចនាសម្ព័ន្ធ៖ អូឌីយ៉ូ វីដេអូ ទិន្នន័យរូបភាព
- ទិន្នន័យមិនមែនជាលេខ៖ ការសម្ភាស, ក្រុមពិភាក្សាស៊ីជម្រៅ (FGD) ការស្ទង់មតិបើក ប្រព័ន្ធផ្សព្វផ្សាយសង្គម អត្ថបទទិនានុប្បវត្តិ (អត្ថបទដែលបានបោះពុម្ពផ្សាយផ្សេងៗ)។

វាអនុញ្ញាតឱ្យអ្នកស្រាវជ្រាវបែងចែកជាថ្នាក់ ជាតម្រៀបនិងរៀបចំព័ត៌មានទៅតាមប្រភេទ ពិនិត្យទំនាក់ទំនងនៅក្នុងទិន្នន័យ និងបញ្ចូលដោយភ្ជាប់ការវិភាគ ការបង្កើតរូបរាង ការស្វែងរក និងម៉ូដែល។




រូបទី៣២. ការវិភាគទិន្នន័យដោយប្រើកម្មវិធីអ៊ិនវីវ៉ូ **NVivo** (២)




រូបទី៣៣. ការវិភាគទិន្នន័យដោយប្រើកម្មវិធីអ៊ិនវីវ៉ូ **NVivo** (៣)

**ការអនុវត្តៈ បង្កើតការសិក្សាស្រាវជ្រាវបែបគុណវិស័យ ដោយខ្លួនឯង**

**ជំហានទី ១ គោលបំណងស្រាវជ្រាវ និងក្របខណ្ឌគោលគំនិត**

- បង្កើតភាពសមហេតុផលរបស់អ្នកដើម្បីធ្វើការស្រាវជ្រាវបែបគុណវិស័យ
- សម្រេចចិត្តលើគោលបំណងស្រាវជ្រាវរបស់អ្នក (ដូចនៅក្នុងសិក្ខាសាលាទី២)
- បង្កើតក្របខណ្ឌគំនិត

**ជំហានទី ២ ការជ្រើសរើសសំណាកស្រាវជ្រាវ**

- សម្រេចចិត្តទៅលើចំនួនប្រជាជនសំណាក ឬតំបន់ណាដែលត្រូវចុះធ្វើការសិក្សា
- សម្រេចចិត្តទៅលើលក្ខណ្ឌអ្វីខ្លះសម្រាប់សំណាកនៅក្នុងការសិក្សា
- កំណត់ពីទំហំសំណាក

**ជំហានទី៣ វិធីសាស្ត្រស្រាវជ្រាវ**

- ជ្រើសរើសវិធីសាស្ត្រស្រាវជ្រាវបែបគុណវិស័យ
- បង្កើតវិធីសាស្ត្រស្រាវជ្រាវនៅក្នុងពិធីសារស្រាវជ្រាវ

**ជំហានទី៤ ការសួរដេញ និងទម្រង់សំណួរ**

- បង្កើតសំណួរសម្ភាស
    - IDI: សំណួរអតិបរមាគឺ១០សំណួរ
    - FGD: សំណួរអតិបរមាគឺ៣ទៅ៥សំណួរ
- បង្កើតការសាកសួរដេញដោលសម្រាប់សំណួរនីមួយៗ
- រៀបចំការណែនាំសម្រាប់អ្នកចុះប្រមូលទិន្នន័យ (រួមទាំង អ្នកសម្របសម្រួល និងជំនួយការផ្នែកកត់ត្រាអំឡុងពេលសម្ភាស)

**ជំហានទី៥ ការប្រមូលទិន្នន័យ**

- បណ្តុះបណ្តាលអ្នកសម្ភាសសម្រាប់ធ្វើការសម្ភាសបែបស៊ីជម្រៅ IDI
- បណ្តុះបណ្តាលអ្នកសម្របសម្រួល និងអ្នកកត់ត្រាសម្រាប់ការធ្វើក្រុមពិភាក្សាស៊ីជម្រៅ FGD
- បណ្តុះបណ្តាលអ្នកប្រមូលទិន្នន័យសម្រាប់ការសង្កេតដោយផ្ទាល់ និងករណីសិក្សា
- ធ្វើការជ្រើសរើសអ្នកចូលរួម
- បង្កើត និងដឹកនាំពីដំណើរការកិច្ចព្រមព្រៀងចូលរួមសម្ភាស
- ដឹកនាំការប្រមូលទិន្នន័យ

**ជំហានទី៦ តារាងបញ្ជីសម្រាប់ការប្រមូលទិន្នន័យ**

- កំណត់ "តួនាទី" ក្នុងការប្រមូលទិន្នន័យសម្រាប់សមាជិកនីមួយៗ
- ពិនិត្យសំណួរសម្ភាស
- រៀបចំឧបករណ៍ថតសំឡេង៖ ឧបករណ៍ឌីជីថល ឬទូរសព្ទស្មាតហ្វូន
- កំណត់អ្នកចូលរួមការសិក្សា
- អនុវត្តដំណើរការទម្រង់កិច្ចព្រមព្រៀងយល់ព្រមមុនពេលសម្ភាស
- ចាប់ផ្តើមដំណើរការប្រមូលទិន្នន័យរបស់អ្នក
- សូមចងចាំការថតសំឡេង និងការកត់ត្រាក្នុងដំណើរការនោះ
- អរគុណអ្នកចូលរួម (ដោយមាន ឬគ្មានអំណោយលើកទឹកចិត្ត)

**ជំហានទី៧ ការគ្រប់គ្រងទិន្នន័យ និងការវិភាគ**

- ការទុកដាក់សំឡេងដែលបានថតរួច
- ការគ្រប់គ្រងទិន្នន័យ
- ការវិភាគទិន្នន័យជាមួយអ៊ិនវីវ៉ូ NVivo ឬកម្មវិធីផ្សេងទៀត។
- សម្រង់ពាក្យពេចន៍

**ជំហានទី៨ បង្កើការបង្ហាញរបស់អ្នក**

- ក្របខណ្ឌគំនិតស្រាវជ្រាវ
- វិធីសាស្ត្រប្រមូលទិន្នន័យ (ទីតាំង សំណាកគំរូ ពេលវេលា)
- ការយល់ព្រមក្នុងការចូលរួម និងក្រមសីលធម៌សម្រាប់ការស្រាវជ្រាវ
- ការគ្រប់គ្រងទិន្នន័យ
- ការវិភាគទិន្នន័យ
- លទ្ធផលនៃការស្រាវជ្រាវ
- ផែនការដើម្បីអនុវត្តនៅក្នុងគម្រោងស្រាវជ្រាវរបស់អ្នក។

សេចក្តីសន្និដ្ឋាន




**រូបទី៣៤. សេចក្តីសង្ខេប និងសេចក្តីសន្និដ្ឋាន**

ក្នុងអំឡុងពេលសិក្ខាសាលានេះ
អ្នកគួរស្វែងយល់អំពីចំណេះដឹងខាងក្រោមអំពីការស្រាវជ្រាវបែបគុណវិស័យនេះ៖

- របៀបនៃការសម្រេចចិត្តក្នុងការជ្រើសរើសការសិក្សាស្រាវជ្រាវបែបគុណវិស័យ ឬបរិមាណ
- របៀបនៃការបង្កើត និងធ្វើការសម្ភាសបែបស៊ីជម្រៅ (IDI)
- របៀបបង្កើត និងធ្វើការពិភាក្សាស៊ីជម្រៅជាក្រុម (FGD)
- របៀបនៃការបង្កើត និងដឹកនាំការធ្វើអង្កេតដោយផ្ទាល់
- របៀបបង្កើត និងប្រមូលទិន្នន័យសម្រាប់ករណីសិក្សា និងរឿងរ៉ាវខ្សែជីវិត
- របៀបគ្រប់គ្រងទិន្នន័យបែបគុណវិស័យ
- របៀបវិភាគ និងបង្ហាញទិន្នន័យការស្រាវជ្រាវបែបគុណវិស័យ

**បន្ទាប់ពីសិក្ខាសាលានេះចប់ យើងនឹងចាប់ផ្តើមនូវដំណើរការស្រាវជ្រាវដូចខាងក្រោម៖**

- ចាប់ផ្តើមការណែនាំ "នៅលើការងារ" របស់យើងសម្រាប់ការបង្កើតពិធីសារស្រាវជ្រាវ
- បង្កើតពិធីការស្រាវជ្រាវរបស់អ្នក (ខែមីនា-មេសា)
- ពិនិត្យ និងកែសម្រួលពិធីសារស្រាវជ្រាវ (ខែមេសា)
- រៀបចំពិធីសារដើម្បីដាក់ជូនការត្រួតពិនិត្យទៅគណៈកម្មាធិការជាតិក្រមសីលធម៌សម្រាប់ការស្រាវជ្រាវផ្នែកសុខភាព (ចុងខែមេសា)
- ប្រមូលទិន្នន័យស្រាវជ្រាវ (ឧសភា)
- រៀបចំសំណុំទិន្នន័យដើម្បីដឹកនាំធ្វើការវិភាគទិន្នន័យ (ឧសភា-មិថុនា)
- រៀបចំបោះពុម្ពផ្សាយអត្ថបទស្រាវជ្រាវ (មិថុនា-សីហា)

## ឯកសារយោង


1. EnagoAcademy (2023). Qualitative vs. Quantitative Research: A Step-Wise Guide to Conduct Research. Retrieved from: https://www.enago.com/academy/qualitative-vs-quantitative-research/ accessed January 2023.
2. Ulin, P.R., Robinson, E.T., Tolley, E.E. (2005) Qualitative Methods in Public Health: A Field Guide for Applied Research.
3. Universitat Wien. (2019) Qualitative Research in International Business. Retrieved from: https://international-business.univie.ac.at/research-publications/qualitative-research/ accessed January 2023.
4. Optimal Workshop (2023). A Beginner's Guide to Qualitative and Quantitative Research. Retrieved from: https://blog.optimalworkshop.com/a-beginners-guide-to-qualitative-and-quantitative-research/ accessed January 2023.
5. Reveall. (2020). How to Combine Quantitative and Qualitative User Research. Retrieved from: https://www.reveall.co/blog/how-to-combine-quantitative-and-qualitative-user-research accessed January 2023.
6. River Campus Libraries, University of Rochester (2023).  Qualitative vs. Quantitative Research. Retrieved from: https://libguides.lib.rochester.edu/c.php?g=472552&p=3237208 accessed January 2023.
7. Avrio. (2022). Mixed Methods Research explained in 7 Minutes. Retrieved from: https://www.avrio.com/blog/mixed-methods-research-explained-in-7-minutes accessed January 2023.
8. LEAD, Krea University (2021). Can Qualitative Research be Rigorous? Part 1: What is Qualitative Research? Retrieved from: https://ifmrlead.org/can-qualitative-research-be-rigorous-part-1-what-is-qualitative-research/ accessed January 2023.
9. Mbuthia, G.W., Olungah, C.O., Ondicho, T. (2018). Health-Seeking Pathway and Factors Leading to Delays in Tuberculosis Diagnosis in West Pokot County, Kenya: A Grounded Theory Study. PLoS One 13(11):e0207995 Retrieved from: https://www.researchgate.net/publication/329260169_Health-seeking_pathway_and_factors_leading_to_delays_in_tuberculosis_diagnosis_in_West_Pokot_County_Kenya_A_grounded_theory_study accessed January 2023.
10. World Bank Group (2015): Multi-Regional Cost-effectiveness and Qualitative Analysis Tools for RBF Impact Evaluations.
11. Qualabear. (2020). 10 Types of Focus Group Participants. Retrieved from: https://qualabear.com/10-types-of-focus-group-participants-and-how-to-handle-them/ accessed January 2023.

## ឧបសម្ព័ន្ធ

## តេស្តមុនវគ្គ ម៉ូឌុលទី ៣

សូមជ្រើសរើសចម្លើយដែលត្រឹមត្រូវនៅក្នុងសំណួរតេស្តមុនវគ្គដូចខាងក្រោម៖

១. តើទម្រង់សំណួរប្រភេទណាខ្លះដែលត្រូវបានប្រើដើម្បីអនុវត្តនៅក្នុងការស្រាវជ្រាវបែបគុណវិស័យ ?
(១) ការគណនាអត្រា (២)ភាគរយនៃមតិ (៣)ទម្រង់សំណួរបើក-បិទ (៤)មាត្រដ្ឋានឡាកខឺត
(៥)ពិន្ទុក្នុងការជ្រើសរើសចម្លើយ

២. តើព័ត៌មានរុករកណាខ្លះអាចប្រមូលបានក្នុងការសិក្សាស្រាវជ្រាវបែបគុណវិស័យ ?
(១)អាកប្បកិរិយា (២) ហេតុផល) (៣) ការជំរុញទឹកចិត្ត(៤) លេខសរុប (៥) គំនិត

៣. តើទិន្នន័យអ្វីខ្លះត្រូវប្រមូលនៅក្នុងការស្រាវជ្រាវបែបគុណវិស័យ ?
(១)ភាគរយ (២) ពាក្យសម្តី (៣)ជារូបភាព (៤) ជាវីដេអូ (៥)ជាលេខ

៤. តើវិធីសាស្ត្រស្រាវជ្រាវអ្វីខ្លះដែលត្រូវបានអនុវត្តនៅក្នុងការស្រាវជ្រាវបែបគុណវិស័យ ?
(១)ការតាមដាន ឬកូហត (២)ក្រុមពិភាក្សាស៊ីជម្រៅ (៣)ការសិក្សាតាមអនឡាញ
(៤)សម្ភាសស៊ីជម្រៅ IDI (៥)ការអង្កេតដោយផ្ទាល់

៥. អ្វីជាភាពខុសគ្នារវាងការស្រាវជ្រាវបែបគុណវិស័យ និងបរិមាណ?
(១)ទម្រង់ទិន្នន័យ (២)ចំនួនរបស់អ្នកចូលរួម (៣)វិធីសាស្ត្រគម្រូសំណាក
(៤)ក្រមសីលធម៌សម្រាប់ការស្រាវជ្រាវ (៥) ការប្រើប្រាស់ស្ថិតិ

៦.
តើត្រូវជ្រើសរើសអ្នកចូលរួមប៉ុន្មាននាក់សម្រាប់ការពិភាក្សាស៊ីជម្រៅនៅក្នុងក្រុមមួយនៃការសិក្សាបែបគុណវិស័យ?
(១)តិចជាងប្រាំនាក់ (២) ពី៥ទៅ១០នាក់ (៣)១៥ទៅ២០នាក់ (៤)២០ទៅ៣០នាក់
(៥)ច្រើនជាង៣០នាក់

៧. តើអ្វីទៅជា "គុទ្ធិពល Hawthorne" នៅក្នុងការសិក្សាអង្កេតដោយផ្ទាល់?
(១) អ្នកចូលរួមមិនព្រមចូលរួម (២)អ្នកចូលរួមនិយាយច្រើនពេក
(៣)អ្នកចូលរួមអនុវត្តបានល្អជាងពេលគេអង្កេត (៤)អ្នកចូលរួមបន្តមើលអ្នកអង្កេតការណ៍
(៥)មិនដឹង

៨. តើអ្នកគិតថារឿងក្តី ឬប្រវត្តិជីវិតរបស់មនុស្សពិសេសណាមួយ
គួរតែត្រូវបានបញ្ចូលក្នុងការស្រាវជ្រាវបែបគុណវិស័យរបស់អ្នកដែរឬទេ?
បាទ (២)ទេ (៣)មិនច្បាស់

៩.
តើកំណត់ត្រាមួយណាដែលត្រូវបញ្ចូលទៅក្នុងដំណើរការគ្រប់គ្រងទិន្នន័យបែបគុណវិស័យសម្រាប់ការវិភាគទិន្នន័យ?
(១)ទម្រង់សំណួរ(២) ការថតសំឡេង(៣) ក្រដាសសម្រាប់ចុះឈ្មោះ(៤) ឯកសារកំណត់ត្រា(៥)
កំណត់ហេតុផ្ទាល់ខ្លួន

១០. តើកម្មវិធីកុំព្យូទ័រ ឬកម្មវិធីអនឡាញណាខ្លះដែលអាចប្រើបានក្នុងការវិភាគទិន្នន័យបែបគុណវិស័យ?
(១) SPSS (២)Excel (៣)អ៊ិនវីវ៉ូNVivo (៤)Epi-Info (៥)Google

សំណួរតេស្តក្រោយវគ្គ

សូមជ្រើសរើសចម្លើយដែលត្រឹមត្រូវនៅក្នុងសំណួរតេស្តមុនវគ្គដូចខាងក្រោម៖

១. តើទម្រង់សំណួរប្រភេទណាខ្លះដែលត្រូវបានប្រើដើម្បីអនុវត្តនៅក្នុងការស្រាវជ្រាវបែបគុណវិស័យ ?
(១) ការគណនាអត្រា (២)ភាគរយនៃមតិ (៣)ទម្រង់សំណួរបើក-បិទ (៤)មាត្រដ្ឋានឡាកខឺត
(៥)ពិន្ទុក្នុងការជ្រើសរើសចម្លើយ

២. តើព័ត៌មានរុករកណាខ្លះអាចប្រមូលបានក្នុងការសិក្សាស្រាវជ្រាវបែបគុណវិស័យ ?
(១)អាកប្បកិរិយា (២) ហេតុផល) (៣) ការជំរុញទឹកចិត្ត(៤) លេខសរុប (៥) គំនិត

៣. តើទិន្នន័យអ្វីខ្លះត្រូវប្រមូលនៅក្នុងការស្រាវជ្រាវបែបគុណវិស័យ?
(១)ភាគរយ (២) ពាក្យសម្តី (៣)ជារូបភាព (៤) ជាវីដេអូ (៥)ជាលេខ

៤. តើវិធីសាស្ត្រស្រាវជ្រាវអ្វីខ្លះដែលត្រូវបានអនុវត្តនៅក្នុងការស្រាវជ្រាវបែបគុណវិស័យ ?
(១)ការតាមដាន ឬក្រូហត (២)ក្រុមពិភាក្សាស៊ីជម្រៅ (៣)ការសិក្សាតាមអនឡាញ
(៤)សម្ភាសស៊ីជម្រៅ IDI (៥)ការអង្កេតដោយផ្ទាល់

៥. អ្វីជាភាពខុសគ្នារវាងការស្រាវជ្រាវបែបគុណវិស័យ និងបរិមាណ?
(១)ទម្រង់ទិន្នន័យ (២)ចំនួនរបស់អ្នកចូលរួម (៣)វិធីសាស្រ្តគម្រូសំណាក
(៤)ក្រមសីលធម៌សម្រាប់ការស្រាវជ្រាវ (៥) ការប្រើប្រាស់ស្ថិតិ

៦.
តើត្រូវជ្រើសរើសអ្នកចូលរួមប៉ុន្មាននាក់សម្រាប់ការពិភាក្សាស៊ីជម្រៅនៅក្នុងក្រុមមួយនៃការសិក្សាបែបគុណ
វិស័យ?
(១)តិចជាងប្រាំនាក់ (២) ពី៥ទៅ១០នាក់ (៣)១៥ទៅ២០នាក់ (៤)២០ទៅ៣០នាក់
(៥)ច្រើនជាង ៣០នាក់

៧. តើអ្វីទៅជា "ឥទ្ធិពល Hawthorne" នៅក្នុងការសិក្សាអង្កេតដោយផ្ទាល់?
(១) អ្នកចូលរួមមិនព្រមចូលរួម (២)អ្នកចូលរួមនិយាយច្រើនពេក
(៣)អ្នកចូលរួមអនុវត្តបានល្អជាងពេលគេអង្កេត (៤)អ្នកចូលរួមបន្តមើលអ្នកអង្កេតការណ៍
(៥)មិនដឹង

៨. តើអ្នកគិតថារឿងក្តី ឬប្រវត្តិជីវិតរបស់មនុស្សពិសេសណាមួយ
គួរតែត្រូវបានបញ្ចូលក្នុងការស្រាវជ្រាវបែបគុណវិស័យរបស់អ្នកដែរឬទេ?
(១) បាទ/ចាស (២)ទេ (៣)មិនច្បាស់

៩.
តើកំណត់ត្រាមួយណាដែលត្រូវបញ្ចូលទៅក្នុងដំណើរការគ្រប់គ្រងទិន្នន័យបែបគុណវិស័យសម្រាប់ការវិភាគទិន្ន័
យ?
(១)ទម្រង់សំណួរ(២) ការថតសំឡេង(៣) ក្រដាសសម្រាប់ចុះឈ្មោះ(៤) ឯកសារកំណត់ត្រា(៥)
កំណត់ហេតុផ្ទាល់ខ្លួន

១០. តើកម្មវិធីកុំព្យូទ័រ ឬកម្មវិធីអនឡាញណាខ្លះដែលអាចប្រើបានក្នុងការវិភាគទិន្នន័យបែបគុណវិស័យ?
(១) SPSS (២) Excel (៣)អុិនវីវ៉ូNVivo (៤) Epi-Info (៥) Google

១១. តើអ្នកបានរៀនចំណេះដឹងថ្មីៗប៉ុន្មានពីសិក្ខាសាលានេះ?
(១) ច្រើនណាស់ (២) តិចតួច (៣) ខ្លះៗ (៤) ដូចមុន (មិនមានអ្វីថ្មីទេ)

១២.
តើផ្នែកណាមួយនៃវគ្គសិក្សាដែលមានប្រយោជន៍ជាងគេក្នុងការបង្កើនសមត្ថភាពស្រាវជ្រាវរបស់អ្នក? (ជម្រើសមានច្រើន)
(១) សេចក្តីផ្តើមនៃការស្រាវជ្រាវបែបគុណវិស័យ (២) វិធីសាស្ត្រស្រាវជ្រាវបែបគុណវិស័យ
(៣) ការអនុវត្តការបង្កើតការស្រាវជ្រាវបែបគុណវិស័យ (៤) ការគ្រប់គ្រងទិន្នន័យ ការវិភាគបែបគុណ
វិស័យ

១៣. តើការពិភាក្សាជាក្រុមមានប្រយោជន៍ចំពោះអ្នកក្នុងការរៀនជំនាញស្រាវជ្រាវដែរឬទេ?
(១) មានប្រយោជន៍ខ្លាំង (២)មានប្រយោជន៍ (៣) មិនមានប្រយោជន៍(៤) មិនមានប្រយោជន៍សោះ

១៤. សរុបមក តើអ្នកពេញចិត្តនឹងសិក្ខាសាលានេះ
ដើម្បីបង្កើនសមត្ថភាពស្រាវជ្រាវរបស់អ្នកទេដែរឬទេ?
(១)ពេញចិត្តណាស់ (២)ពេញចិត្ត (៣)មិនពេញចិត្ត (៤) មិនពេញចិត្តសោះ

១៥. តើអ្នកនឹងស្នើអ្វីមួយដើម្បីកែលម្អការបណ្តុះបណ្តាលស្រាវជ្រាវដែរឬទេ?(សំណួរបើកៈ សរសេរយោបល់អ្នក)
(សំណួរបើកៈ សូមសរសេរនូវសំណូមពររបស់អ្នក)

ចម្លើយសម្រាប់តេស្តមុន និងក្រោយវគ្គ

1. (៣)
2. (១), (២), (៣), (៥)
3. (២), (៣). (៤)
4. (២), (៤), (៥)
5. (១), (២), (៣), (៥)
6. (២)
7. (៣)
8. (១)
9. (១), (២), (៤), (៥)
10. (២), (៣)

This publication was produced with the support of the United States Agency for International Development (USAID) under the terms of the TB Data, Impact Assessment and Communications Hub (TB DIAH) Associate Award No. 7200AA18LA00007. TB DIAH is implemented by the University of North Carolina at Chapel Hill, in partnership with John Snow, Inc. Views expressed are not necessarily those of USAID or the United States government. PR-23-004 TB